# កំណែទម្រង់វិទ្យាស្ថានជាតិអប់រំ

## ឆ្ពោះទៅមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនប្រកបដោយឧត្តមភាព










២០២៥

# កំណែទម្រង់វិទ្យាស្ថានជាតិអប់រំ

## ឆ្ពោះទៅមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនប្រកបដោយឧត្តមភាព




**ឧត្តមភាព គុណភាព សុចរិត សមធម៌ នវានុវត្តន៍**

ក្រសួងអប់រំ យុវជន និងកីឡា

**វិទ្យាស្ថានជាតិអប់រំ**

អគារលេខ ១២៣ មហាវិថីព្រះនរោត្តម

សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ៖ (855) 23 238 816

អ៊ីម៉ែល៖ info@nie.edu.kh

គេហទំព័រ៖ www.nie.edu.kh

**កំណែទម្រង់វិទ្យាស្ថានជាតិអប់រំ៖ ឆ្ពោះទៅមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនប្រកបដោយឧត្តមភាព**

អ្នករៀបរៀង៖ បណ្ឌិត ឌី ខាំបូលី និង បណ្ឌិត គួយ សូគាន

បណ្ណាធិការ៖ លោក ប៊ុត សុផល

អ្នករចនាទំព័រ៖ លោកស្រី ប៉ាត ចាន់ណេង

រក្សាសិទ្ធិគ្រប់យ៉ាង © ឆ្នាំ២០២៥ ដោយវិទ្យាស្ថានជាតិអប់រំ

មិនមានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានយកទៅសរសេរឡើងវិញ ឬប្រើប្រាស់ក្នុងទម្រង់ ឬមធ្យោបាយបែបណាក៏ដោយ ដែលរួមមានទាំងការថតចម្លង ការកត់ត្រា ឬការថតទុកក្នុងប្រព័ន្ធផ្ទុកព័ត៌មានផ្សេងៗទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានជាតិអប់រំឡើយ។

គំនិតរចនាក្រប និងតួសៀវភៅដោយ៖ អង្គការស៊ីប៉ា និង បណ្ឌិត ឌី ខាំបូលី

9789924342236

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥

# មាតិកា


អារម្ភកថា ........ ១

ជំពូក១ ប្រវត្តិវិទ្យាស្ថានជាតិអប់រំ ........ ៣

ជំពូក២ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ១៧

១. ការសាងសង់អគារមហាវិទ្យាល័យគរុកោសល្យ ........ ១៨

២. ការសាងសង់អគារបណ្ណាល័យ សម្តេចព្រះសង្ឃរាជ ជួន ណាត ........ ២៧

៣. ការជួសជុលកែលម្អអគារបេតិកភណ្ឌ អគារសិក្សា និងអគារការិយាល័យ ........ ៣៨

៤. ការសាងសង់របង ខ្លោងទ្វារ និងខឿនព័ទ្ធជុំវិញ ........ ៤៨

៥. ការរៀបចំសួនច្បារ ទីលានកីឡា ចំណតយានជំនិះ អាហារដ្ឋាន ........ ៥១

៦. ការរៀបចំប្រព័ន្ធផ្លូវ ភ្លើង ទឹក លូ សុវត្ថិភាព និងបច្ចេកវិទ្យា ........ ៥៣

ជំពូក៣ ការបណ្តុះបណ្តាលដំបូង ........ ៥៧

១. ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ........ ៥៧

២. សកម្មភាពក្រៅម៉ោងសិក្សា ........ ៦១

ក្លឹបសិក្សា ........ ៦១

ការតាំងពិព័រណ៍អប់រំ ........ ៦២

ការអប់រំស្វែម និងពិសោធន៍វិទ្យាសាស្ត្រ ........ ៦៣

បណ្ណាល័យ ........ ៦៥

សុខភាពសិក្សា ........ ៦៥

ការអនុវត្តវិធីសាស្ត្របង្រៀន ........ ៦៥

សិក្ខាសាលា និងបាឋកថា ........ ៦៥

ទស្សនកិច្ចសិក្សា ........ ៦៥

ការបញ្ចូលបច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិតសម្រាប់ការបង្រៀននិងរៀន ........ ៦៦

ជំពូក៤ ការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ ........ ៦៩

ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រ ........ ៦៩

១. ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ ........ ៦៩

២. ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ........ ៧១

៣. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រងអប់រំ ........ ៧២

៤. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិធីសាស្ត្របង្រៀនភាសាបារាំង ........ ៧៤

ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការអប់រំ ........ ៧៥

១. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអធិការកិច្ចអប់រំ ........ ៧៥

២. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលារៀន ........ ៧៦

៣. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ........ ៧៧

ដេប៉ាតឺម៉ង់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ........ ៧៨

១. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញគរុកោសល្យ និងវិធីសាស្ត្របង្រៀន ........ ៧៨

២. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញនាយកសាលារៀន ........ ៧៩

៣. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញអធិការកិច្ច ........ ៧៩

៤. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញការគ្រប់គ្រងបណ្ណាល័យ ............................................ ៨០
៥. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញការអប់រំស្នេហ............................................................ ៨០

ជំពូក៥ ការស្រាវជ្រាវអប់រំ និងនវានុវត្តន៍.................................................................................................. ៨៣
១. ការស្រាវជ្រាវអប់រំ.......................................................................................................................... ៨៣
២. បណ្ណាល័យ.................................................................................................................................... ៨៤

# អារម្ភកថា

សៀវភៅ **«កំណែទម្រង់វិទ្យាស្ថានជាតិអប់រំ៖ ឆ្ពោះទៅមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនប្រកបដោយឧត្តមភាព»** ត្រូវបានតាក់តែងឡើង ដើម្បីបង្ហាញអំពីការធ្វើកំណែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយនៅក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនមួយដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ និងជាគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូដែលមានអាយុកាលជាងមួយរយឆ្នាំមកហើយ ក្នុងគោលដៅធានាឱ្យបាននូវឧត្តមភាព គុណភាព សមធម៌ និងនិរន្តរភាពនៃការបណ្ដុះបណ្ដាលគ្រូបង្រៀន។

មូលធនមនុស្សនៃប្រជាជាតិមួយពឹងអាស្រ័យលើគុណភាពនៃការអប់រំ ដែលចាប់ផ្ដើមចេញដំណើរពីគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន និងសាលារៀន។ នាយកល្អ គ្រូល្អ និងសិស្សល្អ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ជាទីកន្លែងដែលត្រូវផ្ដល់នូវនវានុវត្តន៍ ឧត្តមានុវត្តន៍ ភាពជាអ្នកដឹកនាំសតវត្សទី២១ រួមទាំងសីលធម៌ ចរិយាធម៌ និងភាពជាគំរូលើគ្រប់ទិដ្ឋភាពទាំងអស់របស់គ្រូបង្រៀន។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយនៅក្នុងវិទ្យាស្ថានជាតិអប់រំ ដោយបានធ្វើការអភិវឌ្ឍទាំងផ្នែករឹង និងផ្នែកទន់ ជាពិសេសការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងការប្រែក្លាយវិទ្យាស្ថានជាតិអប់រំ ឱ្យទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ។

សមិទ្ធផលសំខាន់ៗក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមាន៖ ១).ការសាងសង់អគារសិក្សាមួយខ្នងដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ២).ការសាងសង់ **បណ្ណាល័យ សម្ដេចព្រះសង្ឃរាជ ជួន ណាត** មួយខ្នង ៣).ការជួសជុលកែលម្អអគារបេតិកភណ្ឌ អគារសិក្សា និងអគារការិយាល័យចំនួន ១៦ ដែលរួមទាំងអគារសិក្សានៃវិទ្យាល័យអនុវត្តន៍ និងសាលាបឋមសិក្សាអនុវត្តន៍ ៤).ការសាងសង់របង ខ្លោងទ្វារ និងខឿនព័ទ្ធជុំវិញ ៥).ការរៀបចំសួនច្បារ ទីលានកីឡា ចំណតយានជំនិះ អាហារដ្ឋាន ប្រព័ន្ធផ្លូវ ប្រព័ន្ធភ្លើង ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធសុវត្ថិភាព និងប្រព័ន្ធបច្ចេកវិទ្យា និង ៦).ការបំពាក់សម្ភារៈសិក្សា បន្ទប់រៀនវៃឆ្លាត ប្រកបដោយបច្ចេកវិទ្យាឌីជីថល បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងសម្ភារៈការិយាល័យទំនើប។

ការអភិវឌ្ឍផ្នែកទន់ រួមមាន៖ ១).ការកែលម្អក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សា-គោល និងឯកសារគាំទ្រជាច្រើនផ្សេងទៀត សម្រាប់គ្រប់កម្មវិធីបណ្ដុះបណ្ដាលទាំងអស់ ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់និស្សិត គរុនិស្សិត ឆ្លើយតបទៅនឹងស្ដង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្ដង់ដាសាលាគរុកោសល្យគំរូ, ២).ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិដល់វិទ្យាស្ថានជាតិអប់រំ សម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦, ៣).ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ដល់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) សម្រាប់រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ ២០២៨, និង៤). ការទទួលស្គាល់វិទ្យាស្ថានជាតិអប់រំ ជាសាលាគរុកោសល្យគំរូ។

សមិទ្ធផលធំៗនៃកំណែទម្រង់វិទ្យាស្ថានជាតិអប់រំដូចបានរៀបរាប់ខាងលើ នឹងក្លាយទៅជាឧត្តមានុវត្តន៍មួយសម្រាប់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនដទៃទៀតទូទាំងប្រទេស។ សមិទ្ធផលនេះនឹងចូលរួមចំណែកប្រកបដោយប្រសិទ្ធភាព និងគុណភាព ក្នុងការធានាបាននូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងឱកាសសិក្សាពេញមួយជីវិតសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះបណ្ដាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍ អង្គការជាតិ និងអន្តរជាតិនានា ដែលបានចូលរួមវិភាគទានយ៉ាងថ្លៃថ្លាជួយឧបត្ថម្ភគាំទ្រដល់ការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ រហូតដល់ទទួលបានលទ្ធផលដ៏ត្រចះត្រចង់។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់គណៈកម្មាធិការកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ ដែលបានខិតខំប្រឹងប្រែងអនុវត្តក្របខណ្ឌកម្មវិធីកំណែទម្រង់ អស់រយៈពេល៤ឆ្នាំ រហូតសម្រេចបានលទ្ធផលគួរជាទីមោទននេះ។ សូមគណៈគ្រប់គ្រង គ្រូឧទ្ទេស និងបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំទាំងអស់បន្តថែរក្សាកេរដំណែលនេះ ដើម្បីជាប្រយោជន៍ដល់កូនចៅយើងជំនាន់ក្រោយៗទៀត។

ថ្ងៃពុធ ១១ កើត ខែ ពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

ជំពូក
១

# ប្រវត្តិវិទ្យាស្ថានជាតិអប់រំ

វិទ្យាស្ថានជាតិអប់រំ គឺជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលមានអាយុកាលជាង១០០ឆ្នាំ និងបានដើរតួនាទីជាប្រវត្តិសាស្ត្រ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា។ ស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញ វិទ្យាស្ថានជាតិអប់រំ គឺជាអង្គភាពមួយក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ដែលផ្តល់ការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្តដល់គ្រូបង្រៀនកម្រិតមធ្យមសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន អធិការ និងមន្ត្រីអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

វិទ្យាស្ថាននេះត្រូវបានផ្លាស់ប្តូរឈ្មោះ និងភារកិច្ចនៃការបណ្តុះបណ្តាលគ្រូបង្រៀនជាបន្តបន្ទាប់ ទៅតាមការវិវត្តនៃដំណាក់កាលសង្គម និងនយោបាយរបស់កម្ពុជា។ វិទ្យាស្ថានជាតិអប់រំត្រូវបានបង្កើតឡើងដំបូងបង្អស់ នៅឆ្នាំ១៩១៤ ដែលមានឈ្មោះដើមថា សាលាបឋមសិក្សាប្រាំងស្វ័ប៊ូដឺវាំង (L'école Français Baudoin) ដែលមានភារកិច្ចបណ្តុះបណ្តាលសិស្សបឋមសិក្សា។

នៅឆ្នាំ១៩២២ ប្រកាសអារេតេ (arrêté)[១] ចុះថ្ងៃទី១០ ខែវិច្ឆិកា បានប្រែក្លាយសាលាបឋមសិក្សាប្រាំងស្វ័ប៊ូដឺវាំងទៅជាផ្នែកមួយនៃសាលាគរុវិជ្ជា (Section Normale) ឬហៅថាផ្នែកគរុវិជ្ជាក្រុមខាងត្បូង ដែលជាឧបសម្ព័ន្ធនៃអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលមានតួនាទីបណ្តុះបណ្តាលគ្រូបឋមសិក្សា។

នៅឆ្នាំ១៩៤២ កន្លែងនេះត្រូវបានប្រែក្លាយជាផ្នែកមួយនៃអនុវិទ្យាល័យព្រះស៊ីសុវត្ថិមានឈ្មោះថា សាលាគរុវិជ្ជាភ្នំពេញ



ទិដ្ឋភាពក្លោងទ្វារចូលខាងមុខពីមហាវិថីព្រះនរោត្តម



ទីធ្លាក្នុងបរិវេណរបស់វិទ្យាស្ថានជាតិគរុកោសល្យក្នុងឆ្នាំ១៩៥៨

---

១ ប្រកាសអារេតេ គឺជាការចុះហត្ថលេខារបស់រ៉េស៊ីដង់ជាន់ខ្ពស់បារាំងលើឯកសារដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។



រូបពីឆ្វេងទៅស្តាំគឺសាស្ត្រាចារ្យ កេង វ៉ាន់សាក់ លោក អ៊ិន រ៉ុន លោក សុន សេន
និងលោកស្រី ស៊ុយ ហ្សាន កេង វ៉ាន់សាក់ ថតឆ្នាំ១៩៦០



ទិដ្ឋភាពសាលសហសិក្សារបស់វិទ្យាស្ថានជាតិគរុកោសល្យឆ្នាំ១៩៥៩
ដែលទីតាំងនេះបច្ចុប្បន្នជាមជ្ឈមណ្ឌលវប្បធម៌សម្តេចតេជោ ហ៊ុន សែន និងលោកជំទាវ



*គរុសិស្សជំនាន់ទី២ នៅវិទ្យាស្ថានជាតិគរុកោសល្យ ១៩៥៩*
*នៅជួរទី១ សាស្ត្រាចារ្យ កេង វ៉ាន់សាក់ អង្គុយទី១០ពីឆ្វេងទៅស្តាំនៅជិតភរិយា លោកស្រី ស៊ុយ ហ្សាន ស្លៀកសំពត់ផ្កា នៅជិត Claude Biessy ស្លៀកខោអាវពណ៌ស ហើយនៅជិតលោកម្ខាងទៀតគឺ លោក សុន សេន ជានាយករងវិទ្យាស្ថាននេះ។ លោក ឡុង សៀម ឈរក្រោយបង្អស់ ទី៤ ពីឆ្វេងទៅស្តាំ និងលោក ឡុច ផ្លែង ឈរក្រោយបង្អស់ទី១២ពីឆ្វេងទៅស្តាំ (រូបថតរបស់សាស្ត្រាចារ្យ ឡុច ផ្លែង ១៩៥៩)*

(L'ecole Normale à Phnom Penh[២]) មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា វិក្រឹតការគ្រូបង្រៀន និងសាស្ត្រាចារ្យបឋមភូមិ ដែលជាបុគ្គលិកអប់រំសាធារណៈ។

នៅឆ្នាំ១៩៥៥ ស្ថាប័ននេះជាកន្លែងជួយបំពេញវិជ្ជាបន្ថែមចំពោះគ្រូបង្រៀនដែលមានវិញ្ញាបនបត្រខាងការហ្វឹកហ្វឺនហាត់ខាងកាយសិក្សា និងកីឡាពីជំនាន់មុនសម្រាប់(ក្រុមខាងត្បូង[៣]) តាមប្រកាសរបស់ក្រសួងសិក្សាធិការជាតិលេខ ២៤១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥៥។

២. ក្រឹត្យលេខ១៩៨២ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤២

៣. នៅឆ្នាំ១៩៣៥ មានការបង្កើតតំបន់អធិការកិច្ចលើសាលាវត្តកែប្រែថ្មីចំនួន២កន្លែង គឺតំបន់ខាងត្បូង(Secteur Sud មានដូចជា ខេត្តកំពត តាកែវ កណ្តាល កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង និងក្រុងភ្នំពេញ)ស្ថិតនៅក្រោមលោកអធិការអ៊ុម ឈាងស៊ុន និងតំបន់ខាងជើង(Secteur Nord មានដូចជា ខេត្តបាត់ដំបង សៀមរាប ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ កំពង់ចាម និងក្រចេះ)នៅក្រោមលោកអធិការចែត្រ ឆែម។

នៅឆ្នាំ១៩៥៨ សាលាគរុវិជ្ជាភ្នំពេញត្រូវបានប្រែក្លាយទៅជាប្រភេទគ្រឹះស្ថានសិក្សាជាន់ខ្ពស់ខាងគរុកោសល្យមាននាមថា វិទ្យាស្ថានជាតិខាងគរុកោសល្យ[៤] មានទីតាំងនៅរាជធានីភ្នំពេញដែលមានភារកិច្ច៖

១. បណ្តុះបណ្តាលលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន
២. បណ្តុះបណ្តាលលើកកម្ពស់វិជ្ជាជីវៈសាស្ត្រាចារ្យបឋមភូមិ និង
៣. ជាមជ្ឈមណ្ឌលប្រមូលឯកសារ និងស្រាវជ្រាវខាងមុខវិជ្ជាគរុកោសល្យ។

នៅឆ្នាំ១៩៦០ វិទ្យាស្ថាននេះបានប្រែក្លាយទៅជាវិទ្យាស្ថានជាតិគរុកោសល្យ[៥] ដែលជាឧបសម្ព័ន្ធមួយរបស់សាកលវិទ្យាល័យខេមរភូមិន្ទ(សាកលវិទ្យាល័យភូមិន្ទភ្នំពេញសព្វថ្ងៃ)។

៤. ព្រះរាជក្រឹត្យលេខ៤៣៨ន.ស.ចុះថ្ងៃទី១០ ខែកក្កដា ១៩៥៨

៥. ព្រះរាជក្រមលេខ៣៦៧ន.ស.ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៦០





*សកម្មភាពបង្រៀន និងរៀនរបស់សាស្ត្រាចារ្យក្នុងសាលសហសិក្សា*
*លើមុខវិជ្ជាវប្បធម៌ទូទៅ និងទស្សនវិទ្យាក្នុងឆ្នាំ១៩៥៩*




*កម្រងរូបថតអនុស្សាវរីយ៍របស់អតីតគរុនិស្សិតមហាវិទ្យាល័យ គរុកោសល្យក្នុងឆ្នាំ១៩៦៨*
*(រូបក្នុងជួរដេកទី២ពីលើចុះក្រោមខាងស្តាំគឺបណ្ឌិតសភាចារ្យ ឃីង ហុកឌី កំពុងរស់នៅប្រទេសបារាំងសព្វថ្ងៃនេះ)*

នៅឆ្នាំ១៩៦៥ វិទ្យាស្ថានជាតិគរុកោសល្យត្រូវបានប្រែក្លាយទៅជាមហាវិទ្យាល័យគរុកោសល្យ[៦] ដែលស្ថិតក្នុងចំណោមមហាវិទ្យាល័យ៥ផ្សេងទៀត ក្រោមការគ្រប់គ្រង និងត្រួតពិនិត្យនៃសាកលវិទ្យាល័យខេមរភូមិន្ទ។ មហាវិទ្យាល័យនេះមានភារកិច្ចបណ្ដុះបណ្ដាលនិស្សិត ដែលបានបញ្ចប់បរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីបានក្លាយជាគ្រូបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ បឋមភូមិ និងមានតួនាទីបណ្ដុះបណ្ដាលអធិការកិច្ចអប់រំ។ សកម្មភាពបណ្ដុះបណ្ដាលនេះបានបន្តរហូតដល់របបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ចូលគ្រប់គ្រងប្រទេសនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។




៦. ព្រះរាជក្រមលេខ២២៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៥

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្នុងពេលដែលក្រុមខ្មែរក្រហមចូលគ្រប់គ្រងប្រទេសកម្ពុជាមហាវិទ្យាល័យគរុកោសល្យត្រូវបានបិទទ្វារទាំងស្រុងដូចគ្រឹះស្ថានអប់រំដទៃទៀតនៅទូទាំងប្រទេសដែរ។ នៅក្នុងរយៈកាលនោះ អគារទាំងអស់ក៏ដូចជាបរិវេណវិទ្យាស្ថានទាំងមូលត្រូវបានប្រែក្លាយជាឃ្លាំងសម្រាប់រក្សាទុកគ្រឿងម៉ាស៊ីនចាស់ៗ និងសម្ភារៈផ្សេងទៀត ព្រមទាំងមានការដាំដើមដូងជាច្រើនដើមព័ទ្ធជុំវិញសាលសហសិក្សា។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មហាវិទ្យាល័យគរុកោសល្យនេះ ត្រូវបានបើកទ្វារឡើងវិញ[៧] ដើម្បីស្តារវិស័យអប់រំឡើងវិញក្រោយពេលបិទទ្វារ ក្នុងរបបខ្មែរក្រហមអស់រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ នៅក្នុងដំណាក់កាលនោះ អតីតមហាវិទ្យាល័យគរុកោលស្ស ត្រូវបានប្រើប្រាស់ជាសាលានយោបាយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងអប់រំ និងជាកន្លែងធ្វើវិក្រឹតការគ្រូបង្រៀនបំប៉នវគ្គនយោបាយ[៨] និងបច្ចេកទេសដល់កម្មាភិបាល បុគ្គលិកអប់រំដែលចូលបម្រើការវិស័យអប់រំក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។

នៅឆ្នាំ១៩៨០ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានប្រែក្លាយសាលានយោបាយទៅជាសាលាគរុកោសល្យ និងវិក្រឹតការមជ្ឈិម[៩] មានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹតការ


Pr. Pèn Navuth et H.E. Hun Sèn, congrès sur l'éducation nationale en 1980.

*ឯកឧត្តម ប៉ែន ណាវុឌ្ឍ រដ្ឋមន្ត្រី ក្រសួងអប់រំជាតិ*
*និងឯកឧត្តម ហ៊ុន សែន នៅក្នុងសន្និបាតអប់រំជាតិ ឆ្នាំ១៩៨០*

ជំនាញខាងគ្រប់គ្រងការអប់រំ និងជំនាញគរុកោសល្យដល់កម្មាភិបាលទទួលបន្ទុកមន្ទីរអប់រំខេត្ត-ក្រុងនាយក-នាយករង និងគ្រូបង្រៀន។

នៅឆ្នាំ១៩៨៦ អនុក្រឹត្យលេខ៨ ចុះថ្ងៃទី១៦ ខែមេសា របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីបានកែប្រែសាលាគរុកោសល្យ និងវិក្រឹតការមជ្ឈិមទៅជាសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ[១០]

---

៧. តាមលិខិតលេខ៣២ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៩ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបង្កើតក្រសួងអប់រំ

៨. សម្តេចតេជោហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពេលអញ្ជើញមកប្រគល់សញ្ញាបត្រដល់គរុនិស្សិតបរិញ្ញាបត្រ+១ តែងលើកឡើងថា «ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសបានឆ្លងផ្លូវពីផ្ទះរបស់ខ្ញុំមកធ្វើបទឧទ្ទេសនាមអំពីស្ថានភាពនយោបាយជាតិ និងអន្តរជាតិ ក្រោយឆ្នាំ១៩៧៩ នៅទីនេះរហូតដល់ពេលយប់ ហើយពេលនោះគ្មានអគ្គិសនីទេ គឺយើងប្រើប្រាស់ម៉ាស៊ីនភ្លើងសម្រាប់ធ្វើបទឧទ្ទេសនាម»។

៩. សេចក្តីសម្រេចលេខ៣៦៨-៨០ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៨០

មានឋានៈស្មើនាយកដ្ឋាន។ សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ គឺជាមជ្ឈមណ្ឌល អប់រំនយោបាយ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេសគ្រប់គ្រង និងមុខជំនាញវិជ្ជាជីវៈកម្រិតឧត្តមសិក្សាជូនដល់កម្មាភិបាល គ្រប់គ្រងវិស័យអប់រំ និងមានភារកិច្ចៈ

១. បណ្ដុះបណ្ដាលវិក្រឹតការកម្មាភិបាលគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ចាប់ពីនាយកសាលាកម្រិតសិក្សាទី២ និងកម្មាភិបាលការិយាល័យអប់រំស្រុកឡើងទៅ
២. បំប៉នគ្រប់មុខជំនាញបម្រើឱ្យវិស័យអប់រំ
៣. ស្រាវជ្រាវវិទ្យាសាស្ត្រគ្រប់គ្រងអប់រំ។

នៅឆ្នាំ១៩៩២ សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំត្រូវបានប្រែក្លាយជាមហាវិទ្យាល័យគរុកោសល្យ[១១] វិញ ដែលជាឈ្មោះដើមកាលអំឡុងឆ្នាំ១៩៦៥។ មហាវិទ្យាល័យគរុកោសល្យមានតួនាទីបណ្ដុះបណ្ដាលនិស្សិតដែលបានបញ្ចប់បរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីក្លាយទៅជាគ្រូកម្រិតសិក្សាទី២ បង្រៀននៅសាលារៀនមធ្យមសិក្សាទុតិយភូមិ[១២] និងគ្រូកម្រិតមូលដ្ឋានភាសាបារាំង។

នៅក្នុងឆ្នាំសិក្សា១៩៩៥-១៩៩៦ មហាវិទ្យាល័យគរុ-កោសល្យបានចាប់ផ្ដើមបំពេញតួនាទី និងមុខងាររបស់ខ្លួនក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀនជាលើកដំបូងសម្រាប់វិទ្យាល័យទូទាំងប្រទេស ក្រោមរូបមន្តបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្របូក១ (BA+1) បណ្ដុះបណ្ដាលគ្រូកម្រិតមូលដ្ឋានភាសាបារាំង-ខ្មែរសម្រាប់អនុវិទ្យាល័យតាមរូបមន្ត ១២+២ និងបណ្ដុះបណ្ដាលអធិការកិច្ចអប់រំគ្រប់កម្រិត។

នៅឆ្នាំ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានប្រែក្លាយមហាវិទ្យាល័យគរុកោសល្យទៅជាវិទ្យាស្ថានជាតិអប់រំ (National Institute of Education) មានឋានៈស្មើអគ្គ-នាយកដ្ឋាន។ វិទ្យាស្ថាននេះមានចក្ខុវិស័យកសាងធនធានមនុស្សបម្រើឱ្យសេចក្ដីត្រូវការនៃការអភិវឌ្ឍវិស័យអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបេសកកម្មបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ចអប់រំ អ្នកធ្វើផែនការអប់រំ និងស្រាវជ្រាវវិទ្យាសាស្ត្របច្ចេក-ទេសអប់រំ ដើម្បីរួមចំណែកអភិវឌ្ឍប្រទេស និងលើកស្ទួយអត្តសញ្ញាណជាតិ។

បច្ចុប្បន្នវិទ្យាស្ថានកំពុងមានបេសកកម្មបណ្ដុះបណ្ដាលនូវកម្មវិធីជាច្រើនរួមមាន៖

១. បណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្តមតាមរូបមន្ត (បរិញ្ញាបត្រ+១) បានចំនួន២៦ជំនាន់ និងបរិញ្ញាបត្រ+២ បានចំនួន២ជំនាន់
២. បណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋានភាសាបារាំងតាមរូបមន្ត (១២+២) បាន២៣ជំនាន់
៣. បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំបាន១៣ជំនាន់
៤. បណ្ដុះបណ្ដាលថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំបាន៥ជំនាន់ និងបណ្ឌិតអប់រំឯកទេសកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនបាន៣ជំនាន់
៥. បណ្ដុះបណ្ដាលអធិការកិច្ចអប់រំបាន៧ជំនាន់
៦. បណ្ដុះបណ្ដាលវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិបាន៧ជំនាន់
៧. បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញប្រឹក្សាគរុកោសល្យបាន៥ជំនាន់
៨. បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញវិធីសាស្ត្របង្រៀនភាសាបារាំងបាន៦ជំនាន់

អនុក្រឹត្យលេខ១៨៩ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ បានប្រែក្លាយវិទ្យាស្ថានជាតិអប់រំឱ្យទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ។ នៅក្នុងរចនាសម្ព័ន្ធថ្មីនេះ វិទ្យាស្ថានចែកចេញជា៤អង្គភាព (ឋានៈស្មើនាយកដ្ឋាន) និងមាន១៤ការិយា-ល័យ /ដេប៉ាតឺម៉ង់។

អង្គភាពទាំង៤រួមមាន៖

១. មហាវិទ្យាល័យគរុកោសល្យ
២. សាលាក្រោយបរិញ្ញាបត្រ
៣. មជ្ឈមណ្ឌលស្រាវជ្រាវអប់រំ និងនវានុវត្តន៍
៤. អង្គភាពកិច្ចការទូទៅ

---

១០. អនុក្រឹត្យលេខ៨ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៨៦
១១. អនុក្រឹត្យលេខ៣៤អនក្រចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩២
១២. អនុក្រឹត្យលេខ០៤ ចុះថ្ងៃទី១១ ខែមីនា ២០០៤

*អង្គការលេខរបស់វិទ្យាស្ថានអប់រំ*



នៅក្នុងអាណត្តិទី៦ នៃរាជរដ្ឋាភិបាលកម្ពុជា (២០១៨-២០២៣) ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាទិភាពដល់ការកែទម្រង់គ្រូបង្រៀន និងកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ នៅក្នុងន័យនេះ ក្រសួងបានបង្កើតគណៈកម្មាធិការកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ ដឹកនាំដោយបណ្ឌិត **ឌី ខាំបូលី** ដើម្បីធ្វើកំណែទម្រង់ ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្នែករឹង) កម្មវិធីសិក្សា (ផ្នែកទន់) និងប្រព័ន្ធដឹកនាំ និងគ្រប់គ្រងដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ។ រយៈពេលបួនឆ្នាំនៃការអនុវត្តក្របខណ្ឌកម្មវិធីកំណែទម្រង់ទាំងពីរដំណាក់កាល(មិថុនា ២០២១-មិថុនា ២០២៥) វិទ្យាស្ថានជាតិអប់រំបានប្រែប្រួលមុខមាត់យ៉ាងខ្លាំង និងមានសក្តានុពលខ្ពស់ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការល្អ និងកសាងបណ្តាញជាមួយដៃគូអប់រំនៅក្នុងតំបន់ និងសាកលលោក និងភាគីពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងការអប់រំ។ វិទ្យាស្ថានក៏មានសក្តានុពលក្នុងការក្លាយខ្លួនទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ដែលមិនត្រឹមតែបណ្តុះបណ្តាលគ្រូក្របខណ្ឌប៉ុណ្ណោះទេ ថែមទាំងបណ្តុះបណ្តាលគ្រូអាជ្ញាបណ្ណ ដើម្បីបំពេញកង្វះខាតគ្រូបង្រៀនទាំងនៅគ្រឹះស្ថានសាធារណៈ និងឯកជន។

វិទ្យាស្ថានជាតិអប់រំមានចក្ខុវិស័យជាមជ្ឈមណ្ឌលឧត្តមភាពក្នុង ការអប់រំគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងការស្រាវជ្រាវ។ វិទ្យាស្ថានមានបេសកកម្មលើកកម្ពស់ការបង្រៀន និងការរៀនសម្រាប់សតវត្សរ៍ទី២១ និងការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់របស់គ្រូបង្រៀន អ្នកដឹកនាំផ្នែកអប់រំ និងអ្នកស្រាវជ្រាវកម្ពុជា ដោយប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគុណតម្លៃស្នូលចំនួន៥ រួមមាន**ឧត្តមភាព គុណភាព សុចរិត សមធម៌ និង នវានុវត្តន៍**។



**ឧត្តមភាព៖** ការប្តេជ្ញាចិត្តរបស់វិទ្យាស្ថានជាតិអប់រំចំពោះឧត្តមភាព គឺជំរុញទាំងគ្រឹះស្ថាន និងបុគ្គលឱ្យខិតខំអនុវត្តខ្ជាប់ខ្ជួននូវរាល់តួនាទី និងភារកិច្ចក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់នូវការអប់រំគ្រូ និងតួនាទីជាប្រវត្តិសាស្ត្រ និងប្រពៃណីជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ ការប្តេជ្ញាចិត្តដើម្បីឧត្តមភាពដែលទាក់ទងពីគ្រប់ផ្នែកទាំងអស់ នៃវិទ្យាស្ថាន មានដូចជាកម្មវិធីសិក្សា ការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត ការជ្រើសរើសបុគ្គលិក សេវាកម្មសិស្ស-និស្សិត-គរុនិស្សិត បរិស្ថានក្នុងបរិវេណវិទ្យាស្ថាន ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំប្រតិបត្តិការប្រចាំថ្ងៃ និងសេវាសហគមន៍។

**គុណភាព៖** វិទ្យាស្ថានជាតិអប់រំខិតខំផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព និងឱកាសសម្រាប់ការសិក្សាពេញមួយជីវិតតាមរយៈការផ្តល់នូវក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងការបណ្តុះបណ្តាលស្របតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និងសមត្ថភាពជំនាញសតវត្សរ៍ទី២១។ ដោយប្រកាន់ជាប់នូវគុណភាពជាស្នូលនៃវិទ្យាស្ថាន វ.ជ.អ. នឹងរួមចំណែកដល់ចក្ខុវិស័យសាលារៀនរបស់ប្រទេសកម្ពុជាឱ្យក្លាយជាមជ្ឈមណ្ឌលអប់រំមួយដែលធានានូវការអប់រំ ប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា និងផលិតគ្រូបង្រៀនប្រកបដោយសមត្ថភាព មានមនសិការ និងវិជ្ជាជីវៈ។ បន្ថែមពីនេះទៀត វិទ្យាស្ថាននឹងផលិតនិស្សិតដែលមានទាំងជំនាញរឹង និងទន់ អាកប្បកិរិយាល្អ និងក្លាយជាពលរដ្ឋសាកលដែលមានគុណភាពខ្ពស់ ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេស និងពិភពលោក។

**សុចរិត៖** វិទ្យាស្ថានជាតិអប់រំ ប្តេជ្ញាចិត្តចំពោះគោលការណ៍តម្លាភាព គណនេយ្យភាព វិន័យ ភាពស្មោះត្រង់ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់នៅក្នុងការអនុវត្តរាល់សកម្មភាពរបស់វិទ្យាស្ថាន។ កិត្តិនាមរបស់វិទ្យាស្ថានជាតិអប់រំនឹងស្វែងរកភាពល្អប្រសើរសម្រាប់គរុនិស្សិត និងនិស្សិតឱ្យឈានមុខគេជានិច្ច។

**សមធម៌៖** វិទ្យាស្ថានជាតិអប់រំប្តេជ្ញាចិត្តចំពោះគោលការណ៍មិនលំអៀង ការគោរពនូវចម្រុះភាព និងជំនឿសាសនាខុសៗគ្នា។ គុណតម្លៃនេះបានជួយបណ្តុះវប្បធម៌គ្រឹះស្ថានក្នុងការផ្តល់ឱកាសសម្រាប់ឧត្តមភាពនៃគ្រូបង្រៀន។

**នវានុវត្តន៍៖** ក្នុងនាមជាមជ្ឈមណ្ឌលស្រាវជ្រាវអប់រំប្រកបដោយនវានុវត្តន៍ វិទ្យាស្ថានជាតិអប់រំព្យាយាមអនុវត្តការស្រាវជ្រាវដោយផ្អែកលើភស្តុតាង ការប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្តសមត្ថភាពអប់រំនៅសតវត្សរ៍ទី២១។ វិទ្យាស្ថានជាតិអប់រំ ព្យាយាមកំណត់ស្តង់ដានៃឧត្តមភាពដើម្បីរក្សាទំនាក់ទំនង និងកែលម្អគុណភាពប្រកបដោយចីរភាព។

គណៈគ្រប់គ្រងវិទ្យាស្ថានជាតិអប់រំចាប់តាំងពីឆ្នាំ១៩៥៨ ដល់បច្ចុប្បន្ន រួមមាន៖

១. សាស្ត្រាចារ្យ **កេង វ៉ាន់សាក់** (១៩៥៨-១៩៦០)
២. សាស្ត្រាចារ្យ **អ៊ិន រ៉ុន** (១៩៦១-១៩៦២)
៣. សាស្ត្រាចារ្យ **អ៊ុយ វ៉ានថុន** (១៩៦២-១៩៦៣)
៤. សាស្ត្រាចារ្យ **ប៉ុង គឹមយន** ជាព្រឹទ្ធបុរស (១៩៦៣-១៩៧៣)
៥. សាស្ត្រាចារ្យ **ឈា អេងឡុច** ជាព្រឹទ្ធបុរស(១៩៧៣-១៩៧៥)។
៦. សមមិត្ត **ធិត ជានូ** (១៩៧៩-១៩៨១)
៧. សមមិត្ត **សោម កុយ** (១៩៨២-១៩៨៣)
៨. សមមិត្ត **អ៊ុំ គឹមផន** (១៩៨៤-១៩៨៩)
៩. សមមិត្ត **សម ព្រហ្មនា** (១៩៩០-១៩៩២)
១០. សាស្ត្រាចារ្យ **នាង មុត** (១៩៩៣-១៩៩៧)
១១. បណ្ឌិត **ឆយ អួន**(១៩៩៤-៩៥) ជំនួសលោកនាយក **នាង មុត** ទៅសិក្សានៅប្រទេសបារាំង
១២. បណ្ឌិត **ធ សោ** (១៩៩៨-២០០៥)
១៣. បណ្ឌិត **អ៊ឹម កុច** (២០០៦-២០១១)
១៤. បណ្ឌិត **សៀង សុវណ្ណា** (២០១១-បច្ចុប្បន្ន)



ពីស្ដាំទៅឆ្វេង ប៉ោង សុធារី កែវ សុប្បូរិន្ទ ម៉ម សុណា ញេប ពិដោ សឹម សុវណ្ណា
លី សុគន្ធា សោម សុម៉ានី ប៊ឹង យុវត្តី ប៊ួយ ផល វង្សី និមល ហ៊ុយ សុភី ឆ្នាំ១៩៨៤
ថតនៅអគារខាងត្បូងពីស្ដាំបន្ទប់ទី២



*ពិធីបិទវគ្គឆ្នាំទី១ (១៩៨៤)*



*ថតនៅឆ្នាំទី២ពីស្ដាំទៅឆ្វេង ១.ចឹង មិថុនា ២.ប៉ោង សុធារី*
*៣.រង្សី និមល ៤.កែវ សុបុប្ផរិទ្ធ ៥.ឯម វុឌ្ឍានី ៦.អ៊ុក កុសល ៧.ហោ គឹមសុកាន*



*ពីស្តាំទៅឆ្វេងជួរឈរ ១.បុត្រ ភក្តី ២.ប៉ក់ សម័យ ៣.ស៊ីវិទ្យានី ៤.គឹមអាន*
*៥.កែវ សុបូរិន្ទ ៦.មិនចាំ ៧.ឡុច វី ៨.អ៊ិ ច័ន្ទវាសនា ៩.ហ៊ិង សុខណ្ណា ១០.មុន្នា ១១.កែ សុវត្ថថាវី ១២.ឡេង មាលា*



ជំពូក
២

# ការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត




**កំណត់សម្គាល់**

| | | | | | | | |
|---|---|---|---|---|---|---|---|
| 1 | អគារ ក (អគ្គនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ) | 7 | អគារ F (វិទ្យាល័យអនុវត្ត) | 13 | អគារ L (ទីចាត់ការវិទ្យាល័យអនុវត្ត) | 19 | ចំណតយានជំនិះ (Parking) |
| 2 | អគារ A (អគាររដ្ឋបាល) | 8 | អគារ G (អគាររដ្ឋបាល) | 14 | អគារ M (ការិយាល័យគណៈគ្រប់គ្រង) | 20 | សួនច្បារ (Garden) |
| 3 | អគារ B (អគាររដ្ឋបាល) | 9 | អគារ H (អគាររដ្ឋបាល) | 15 | អគារ N (អគារពិសោធន៍) | 21 | តារាងបាល់បោះ (Basketball Field) |
| 4 | អគារ C (នាយកដ្ឋានបណ្តុះបណ្តាល) | 10 | អគារ I (មជ្ឈមណ្ឌលNGPRC) | 16 | អគារ O (បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត) | 22 | កន្លែងថតរូប (Photo Session) |
| 5 | អគារ D (នាយកដ្ឋានវិក្រឹតការ) | 11 | អគារ J (បឋមសិក្សាអនុវត្ត) | 17 | អគារ B07 (អគារសាលាក្រោយបរិញ្ញាបត្រ) | 23 | បន្ទប់អគ្គិសនី (TEDC) |
| 6 | អគារ E (អគាររដ្ឋបាល) | 12 | អគារ K (សាលប្រជុំ) | 18 | អគារ P (មហាវិទ្យាល័យគរុកោសល្យ) | T1 | បង្គន់អនាម័យ (Toilet) |

វិទ្យាស្ថានជាតិអប់រំមានទីតាំងនៅអគារលេខ១២៣ មហាវិថីព្រះនរោត្តម សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានផ្ទៃក្រឡាសរុបចំនួន២៧,១៩៨ម៉ែត្រក្រឡា មានអគារចំនួន១៨ខ្នង មានបុគ្គលិកអប់រំសរុបចំនួន២៥៥នាក់ ក្នុងនោះស្ត្រី១០២នាក់។

បរិវេណវិទ្យាស្ថានជាតិអប់រំទាំងមូល ចែកចេញជាពីរតំបន់ធំៗ។ ខាងស្តាំដៃចូលពីខ្លោងទ្វារធំខាងត្បូង គឺជាតំបន់រដ្ឋបាល និងខាងឆ្វេងដៃគឺជាតំបន់សិក្សា។ បរិវេណនេះចែកចេញជា៤អង្គភាពដែលរួមមាន៖

១.វិទ្យាស្ថានជាតិអប់រំមានអគារចំនួន១២ខ្នង (អគារ A, B, E, G, H, I, K, M, N, O, P និង B07)
២.អគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការចំនួន ៣ ខ្នង (អគារ ក, C និង D)
៣.វិទ្យាល័យអនុវត្តមានអគារចំនួន២ខ្នង (អគារ F និង L)
៤. សាលាបឋមសិក្សាអនុវត្តមានអគារចំនួន១ខ្នង (អគារ J)

ក្រោមក្របខណ្ឌកម្មវិធីកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ និងគម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2) វិទ្យាស្ថានជាតិអប់រំទទួលបាន៖ (១) ការសាងសង់អគារសិក្សាមួយខ្នង (២) ការសាងសង់អគារបណ្ណាល័យមួយខ្នង (៣) ការជួសជុលកែលម្អអគារបេតិកភណ្ឌ អគារសិក្សា និងអគារការិយាល័យចំនួន១៦ខ្នង ដែលរួមទាំងអគារសិក្សានៃវិទ្យាល័យអនុវត្ត និងបឋមសិក្សាអនុវត្ត (៤) ការសាងសង់របង ខ្លោងទ្វារ និងខឿនព័ទ្ធជុំវិញ (៥) ការរៀបចំសួនច្បារ ទីលានកីឡា ចំណតយានជំនិះ អាហារដ្ឋាន (៦) ការរៀបចំប្រព័ន្ធផ្លូវ ប្រព័ន្ធភ្លើង ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធសុវត្ថិភាព និងប្រព័ន្ធបច្ចេកវិទ្យា និង (៧) ការបំពាក់សម្ភារៈសិក្សា បន្ទប់រៀនវៃឆ្លាត ប្រកបដោយបច្ចេកវិទ្យាឌីជីថល បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ និងសម្ភារៈការិយាល័យទំនើប។

## ១.ការសាងសង់អគារមហាវិទ្យាល័យគរុកោសល្យ

អគារមហាវិទ្យាល័យគរុកោសល្យ ត្រូវបានបញ្ចុះបឋមសិលាសាងសង់នៅថ្ងៃទី២៣ កញ្ញា ២០២១ និងបានបញ្ចប់ការសាងសង់នៅខែមីនា ឆ្នាំ២០២៤។ អគារសិក្សានេះត្រូវបានបំពាក់គ្រឿងសង្ហារិម សម្ភារៈការិយាល័យ និងសម្ភារៈសិក្សារួចរាល់ ដោយត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤។ អគារសិក្សានេះរួមមាន បន្ទប់សិក្សាចំនួន៣៦ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ៤ បន្ទប់កុំព្យូទ័រ១ ដែលមានកុំព្យូទ័រ៦០គ្រឿង មជ្ឈមណ្ឌលសិក្សា អេឡិចត្រូនិក បន្ទប់សាស្ត្រាចារ្យ បន្ទប់គណៈគ្រប់គ្រងមហាវិទ្យាល័យគរុកោសល្យ និងដេប៉ាតឺម៉ង់ទាំង៣ បណ្ណាគារ កាហ្វេ និងអាហារដ្ឋាន។ គ្រប់បន្ទប់រៀនទាំងអស់ត្រូវបានបំពាក់សម្ភារៈថ្នាក់រៀនវៃឆ្លាត និងឧបករណ៍បច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលសតវត្សរ៍ទី២១។ អគារសិក្សានេះដើរតួនាទីយ៉ាងសំខាន់ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន កម្រិតឧត្តមបរិញ្ញាបត្របូក២ (BA+2)។

អគារមហាវិទ្យាល័យគរុកោសល្យ មានទំហំបណ្តោយប្រវែង ៦២ម ទទឹងប្រវែង២៥ម និងកម្ពស់២៣,៤៩ម មាន៥ជាន់ស្មើនឹង៤២បន្ទប់ និងមានចំណតរថយន្តក្រោមដី១ជាន់។ អគារដ៏ធំនេះសាងសង់ដោយកងវិស្វកម្មសម្តេចតេជោ ហ៊ុន សែន។


អំណោយ សម្តេចតេជោ ហ៊ុន សែន និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី
មហាវិទ្យាល័យគរុកោសល្យ
FACULTY OF PEDAGOGY

*រូបមើលពីមុខ*


IN
OUT
SECURITY CABIN
PUMPING STATION
GENERATOR
Total Parking: 30
9000
63000

ប្លង់ជាន់ក្រោមដី








ប្លង់ជាន់ផ្ទាល់ដី



ច្រកចូលមហាវិទ្យាល័យគរុកោសល្យ



សាលប្រជុំ




អាហារដ្ឋាន និងគរុកាហ្វេ



អាហារដ្ឋាន




ប្លង់ជាន់ទី១





បន្ទប់សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រ



ថ្នាក់រៀន


02.





បន្ទប់ *Smart Classroom*



បន្ទប់ពិសោធន៍



ប្លង់ជាន់តេរ៉ាស់



ទិដ្ឋភាពតំបន់វិមានឯករាជ្យ មើលពីវិទ្យាស្ថានជាតិអប់រំទៅ



ច្រកទល់មុខមហាវិទ្យាល័យគរុកោសល្យ និងអគារសាលាក្រោយបរិញ្ញាបត្រ

## ២. ការសាងសង់អគារបណ្ណាល័យ សម្ដេចព្រះសង្ឃរាជ ជួន ណាត

បណ្ណាល័យសម្ដេចព្រះសង្ឃរាជ ជួន ណាត ត្រូវបានរចនាឡើងដោយឈរលើទស្សនាទានបីរួមគ្នា អប់រំ វប្បធម៌ និងសាសនា។ អគារនេះមានទម្រង់ជាអក្សរ «រ» នៅពីលើអក្សរ «អ» ដែលតំណាងឱ្យការអប់រំ ប្រើប្រាស់ខឿននិងផ្ដាភ្ជីប្រាសាទអង្គរ ដែលតំណាងឱ្យវប្បធម៌ជាតិ និងមានដំបូលលើមាត់ទ្វាររាងដូចដំបូលវត្ត ដែលតំណាងឱ្យពុទ្ធសាសនា។ បណ្ណាល័យនេះត្រូវបានបញ្ចុះបឋមសីលាសាងសង់នៅថ្ងៃទី ២៩ វិច្ឆិកា ២០២៣ និងបញ្ចប់នៅខែមីនា ឆ្នាំ២០២៥ ដោយប្រើរយៈពេលសាងសង់សរុប៥៤០ថ្ងៃ។ បណ្ណាល័យមានប្រមូលផ្ដុំឯកសារស្ដីពីការអប់រំរបស់កម្ពុជា ចាប់តាំងពីមុនសម័យអាណានិគមបារាំង រហូតដល់ពេលបច្ចុប្បន្ន និងរួមទាំងបណ្ណាល័យទូរនិម្មិត ដែលសិស្ស និស្សិត គ្រូបង្រៀន និងអ្នកស្រាវជ្រាវអាចចូលមើល និងស្រាវជ្រាវបានដោយសេរី។ បណ្ណាល័យមានតម្កល់សៀវភៅពាក់ព័ន្ធនឹងការអប់រំជាង២ម៉ឺនក្បាល សាលអានដែលមានច្រើនទម្រង់ បន្ទប់ស្វ័យសិក្សា និងធ្វើការជាក្រុម បន្ទប់ស្ទូឌីយ៉ូសម្រាប់ស្ដាប់និងមើលវីដេអូ បន្ទប់កុំព្យូទ័រសម្រាប់ស្រាវជ្រាវឯកសារ បន្ទប់ប្រជុំ ការិយាល័យធ្វើការរបស់បណ្ណារក្ស បន្ទប់រក្សាឯកសារក្រោមដី បន្ទប់ថែទាំទារក។ ដោយទទួលបានមូលនិធិគាំទ្រពីគម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2) ដែលជាមូលនិធិកម្ចីពីធនាគារអភិវឌ្ឍអាស៊ី (ADB) បណ្ណាល័យនេះនឹងក្លាយទៅជាបណ្ណាល័យឯកទេសអប់រំសតវត្សរ៍ទី២១ដំបូងបង្អស់នៅកម្ពុជា។




*ខ្លោងទ្វារបណ្ណាល័យ*

អគារបណ្ណាល័យនេះមានទំហំបណ្តោយប្រវែង២៣,៧០.ម ទទឹងប្រវែង១៥,0.ម និងកម្ពស់២២,៦២.ម មានកម្ពស់ ៥ជាន់ និងជាន់ក្រោមដីមួយជាន់ ដំបូលទៃវ៉ាស់ មានផ្ទៃក្រឡាសំណង់សរុប២៧,២៩៨.០៨ម៉ែត្រការ៉េ។



**ពិធីបញ្ចុះបឋមសិលាសាងសង់៖** អគារបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត ថ្មីបានធ្វើពិធីបញ្ចុះបឋមសិលាសាងសង់នៅថ្ងៃពុធ ២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា។



*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អុជទៀនក្រុងពាលីសុំពរជ័យ ចាប់ដំណើរការសាងសង់*



*ពិធីកាត់សីមាបញ្ចុះបឋមសិលាសាងសង់*



*ក្រុមវិស្វករសំណង់ក្រុមហ៊ុន ខេ ប៊ី អេច ខនស្ត្រាក់សិន*

**ការសិក្សាពិសោធន៍ភូគព្ភសាស្ត្រ៖** ដើម្បីសុវត្ថិភាព និងភាពរឹងមាំរបស់សំណង់អគារបណ្ណាល័យថ្មី ចាំបាច់ត្រូវសិក្សា និងគណនាឱ្យបានជាក់លាក់នូវផ្នែកគ្រឹះរបស់អគារ។ ក្រុមហ៊ុនសហគ្រាសសិក្សាស្រាវជ្រាវ គូរប្លង់បានចាប់ផ្តើមការងារខួងនៅការដ្ឋានចំនួន០៣រណ្តៅក្នុងជម្រៅ៣៥.ម និងការងារនៅក្នុងមន្ទីរពិសោធន៍ចាប់ពីថ្ងៃទី១២ ខែមីនា ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២។ លទ្ធផលនៃការសិក្សាពិសោធន៍ភូគព្ភសាស្ត្រអនុវត្តដោយក្រុមហ៊ុនសហគ្រាសសិក្សាស្រាវជ្រាវគូរប្លង់ “Research & Design Enterprise, RDE”។

**ការគណនាគ្រឹះ និងដំណើរការសាងសង់៖** យោងតាមលទ្ធផលនៃការសិក្សាពិសោធន៍ភូគព្ភសាស្ត្រ វិស្វករគ្រឿងផ្គុំបានគណនាដោយប្រើវិធីខួងចាក់ មានមុខកាត់ទំហំ ០,៨០ម ជម្រៅ២៨ម គិតពីនីវ៉ូ០,០០ ដែលមានគ្រឹះសរុប ៤៤ដើម។




*ប្លង់សសរគ្រឹះ និងតំណាក់កាលនៃការខួងគ្រឹះ*



*សកម្មភាពខួងសសរគ្រឹះ*

**ការធ្វើពិសោធន៍លើសម្ភារៈប្រើប្រាស់មុនពេលសាងសង់៖** មុនពេលប្រើប្រាស់ រាល់សម្ភារៈសំណង់ទាំងអស់ត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ដើម្បីពិសោធន៍ មានដូចជា ដែកសរសៃដែលត្រូវប្រើប្រាស់គ្រប់ខ្នាត ដែកខ្សែកាប (Post tension steel) ឥដ្ឋតាន់ ឥដ្ឋប្រហោង សង្កត់ដុំបេតុង។ល។







*ចំណងជើងរូបភាព*

**ការពិនិត្យសសរគ្រឹះក្នុងដី លទ្ធភាពទ្រទ្រង់របស់សសរគ្រឹះ និងជញ្ជាំងស៊ីផាល៖** បន្ទាប់ពីបញ្ចប់ការងារបេតុងសសរគ្រឹះចំនួន៤៤ដើមរួចរាល់ ការងារបន្ទាប់គឺការធ្វើតេសសូនីច (Cross-hole Sonic logging (CSL) ចំនួន១៣២បំពង់ ដើម្បីពិនិត្យរកភាពស្អាតនៃសសរគ្រឹះដែលបង្កប់ក្នុងដីក្នុងជម្រៅ២៨.ម និងការធ្វើតេស្ត PDA ដើម្បីរកលទ្ធភាពទ្រទ្រង់របស់សសរគ្រឹះមួយដើម។ ការធ្វើពិសោធន៍ទាំងពីរប្រភេទនេះទទួលបានលទ្ធផលល្អទាំងអស់យោងតាមរបាយការណ៍លម្អិតរបស់ក្រុមហ៊ុន Dynamic Growth E & C Co., Ltd។






*ចំណាងជើងរូបភាព*

**ការកាត់ក្បាលសសរគ្រឹះ និងចាក់បេតុងជើងតាងគ្រឹះ**

**កម្រាលខណ្ឌជាន់ក្នុងដី និងជញ្ជាំងទប់ដី៖** វិស្វករគ្រឿងផ្គុំបានគណនាកម្រាលខណ្ឌជាន់ក្នុងដី និងជញ្ជាំងទប់ដីជាប្រភេទបេតុងអារម៉េ។



*ការរៀបចំនៃការកាត់សសរគ្រឹះ*



*ការចងដែលផ្ទឹម និងកម្រាលនៅជាន់ក្រោមដី*



*ជើងតាងពេលចាក់រួចរាល់*



*ការចងដែលជញ្ជាំងទប់ដីនៅជាន់ក្រោមដី*



*ការរៀបចំដែកជើងតាង និងការងារបិតពុម្ព*

**ការគណនាកម្រាលខណ្ឌពីជាន់ផ្ទាល់ដីដល់ជាន់ទៅរ៉ាស់៖** វិស្វករគ្រឿងផ្គុំបានគណនាកម្រាលខណ្ឌ ជាប្រភេទខ្សែកាប (Post Tension Slab) ដែលអាចអនុញ្ញាតឱ្យមានល្វែងធំៗពីសសរមួយទៅសសរមួយទៀត។



*សកម្មភាពត្រួតពិនិត្យការរាយខ្សែកាបមុនចាក់បេតុង*



*ចំនួនខ្សែកាបក្នុងមួយបំពង់*



*ការរៀបចំ និងកំណត់ទំហំពុម្ពសសរ*

**សកម្មភាពខ្លះៗរបស់ថ្នាក់ដឹកនាំគម្រោង និងប្រតិភូពី ADB ចុះពិនិត្យការងារ**

ជារឿយៗ ថ្នាក់ដឹកនាំគម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ វិស្វករនាយកដ្ឋានសំណង់ និងប្រតិភូមកពីធនាគារអភិវឌ្ឍអាស៊ី (ADB) បានចុះពិនិត្យការងារសាងសង់ និងពិនិត្យផ្នែកសុវត្ថិភាពកម្មករ និងជាងនៅអគារជួសជុល អគារបណ្ណាល័យថ្មីរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត និងបានផ្តល់អនុសាសន៍លើផ្នែកបច្ចេកទេស និងសុវត្ថិភាពក្នុងការកែសម្រួលឱ្យកាន់តែប្រសើរឡើង។



*ឯកឧត្តមប្រធានគម្រោងចុះពិនិត្យការងារ*

## ខ្លោងទ្វារបណ្ណាល័យ
## សម្តេចព្រះសង្ឃរាជ ជួន ណាត

ខ្លោងទ្វារបណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត រចនាឡើងអំពីដែកស្និត ដែលមានក្បាច់រចនាជាក្បាច់ភ្ញីទេសក្នុងទម្រង់បញ្ឈរ កំពូលទ្វារលម្អដោយក្បាច់អង្គរក្នុងទម្រង់ត្របកឈូកចំពីមុខ ចំណែកកំពូលទ្វារបន្ទាប់ លម្អដោយក្បាច់វង់ហៀនភ្ញីទេសបង្កប់ដោយក្បាច់ត្របក ឈូកវង់ហៀនចំហៀងសងខាង។




*ខ្លោងទ្វារច្រកចូលអគារបណ្ណាល័យ*



*ការដកស្រង់ក្បាច់ខ្មែរមកបំពាក់លើខ្លោងទ្វារដែកស្និត*



*អត្ថន័យនៃក្បាច់នីមួយៗនៅលើខ្លោងទ្វារ*



*ប្រភពនៃការដកស្រង់ក្បាច់ខ្មែរមកបំពាក់លើខ្លោងទ្វារ*



*ក្បាច់ភ្ញីទេសក្នុងទម្រង់បញ្ឈរ*



*ក្បាច់អង្គរក្នុងទម្រង់ត្របកឈូកចំពីមុខ*




អគារបណ្ណាល័យមើលពីមហាវិថីព្រះសីហនុ

គ្រប់អគារទាំងអស់សុទ្ធតែទទួលបានការផ្គត់ផ្គង់សម្ភារសិក្សា និងសម្ភារការិយាល័យទំនើប ដើម្បីធានាបាននូវយន្តការនៃការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព។ គម្រោង USESDP2 បានផ្គត់ផ្គង់សម្ភារៈពិសោធន៍សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដី-បរិស្ថានវិទ្យា) នៅក្នុងបន្ទប់ពិសោធន៍ សម្រាប់ជាការប្រើប្រាស់របស់គ្រូឧទ្ទេស គរុនិស្សិត និងសិស្សនៅវិទ្យាល័យអនុវត្ត។ ឧបករណ៍ ទាំងអស់នោះប្រើប្រាស់សម្រាប់សកម្ម-ភាព ស្រាវជ្រាវរបស់គ្រូឧទ្ទេស ដើម្បីយកទៅបំប៉នបន្ថែមដល់គ្រូបង្រៀននៅតាមវិទ្យាល័យ និងសកម្មភាពស្រាវជ្រាវរបស់គរុនិស្សិត សម្រាប់យកទៅបង្រៀននៅតាមវិទ្យាល័យនៅពេលពួកគាត់បញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិអប់រំផងដែរ។ គម្រោងក៏បានផ្គត់ផ្គង់កុំព្យូទ័រលើតុចំនួន១២០គ្រឿង ដើម្បីបំពាក់បន្ទប់ ICT ចំនួន៤បន្ទប់សម្រាប់គរុនិស្សិតសិក្សា និងស្រាវជ្រាវ បំពាក់ម៉ាស៊ីន Server មួយឈុតសម្រាប់រក្សាទិន្នន័យទាំងឡាយរបស់វិទ្យាស្ថាន និងការអនុវត្តការគ្រប់គ្រងអភិបាលកិច្ចឌីជីថល ទិញកុំព្យូទ័រយួរដៃចំនួន២៦៥គ្រឿង ចែកជូនគ្រូឧទ្ទេស និងបុគ្គលិកតាមការិយាល័យ និងដេប៉ាតឺម៉ង់ប្រើប្រាស់ និងដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឌីជីថល សម្រាប់ការរៀន និងការបង្រៀន។



*បន្ទប់ ICT*



*បន្ទប់ឌីជីថល*



*ការិយាល័យ*



*បន្ទប់សិក្សា*

## ៣.ការជួសជុលកែលម្អអគារបេតិកភណ្ឌ អគារសិក្សា និងអគាររដ្ឋបាល

អគារបេតិកភណ្ឌមានចំនួន៩ខ្នង ដែលមានអាយុកាលជាង ១០០ឆ្នាំ ត្រូវបានស្តារ និងជួសជុលឡើងវិញដោយបានសិក្សាយ៉ាងហ្មត់ចត់តាមរចនាបថដើមទាំងស្រុង។ អគារទាំងនេះមានសភាពទ្រុឌទ្រោមខុសៗគ្នា ដែលអគារចំនួនពីរ (អគារ G និង H) មានសភាពទ្រុឌទ្រោមខ្លាំង។

ដោយមានសភាពទ្រុឌទ្រោមខ្លាំងពេក ក្រុមវិស្វករបានរុះរើទាំងស្រុងនៃហេដ្ឋារចនាសម្ព័ន្ធចាស់ៗរួមមាន ដំបូល ទ្វារ បង្អួច ជណ្តើរឈើដែលពុកផុយដោយអាយុកាលច្រើនឆ្នាំ និងការបំផ្លាញដោយសត្វល្អិត។ ក្រុមជាងបានបកបាយអចាស់ចេញទាំងអស់ និងការ៉ូបាតដែលមានលក្ខណៈពុកផុយរបេះចេញពីជញ្ជាំងនៃផ្នែកអគារជាច្រើនតាំងពីជាន់ក្រោមរហូតដល់ដំបូល។ ក្រុមវិស្វករបានប្រើប្រាស់សម្ពាធទឹកបាញ់លាងសម្អាត កម្ទេចកំទីដែលសេសសល់លើជញ្ជាំង មានដូចជាធូលីដី ខ្សាច់ និងបាយអដែលពុកផុយ បៀកស៊ីម៉ង់ត៍ការតាមរ៉ងឥដ្ឋឱ្យបានសព្វល្អ រួចលាបទឹកស៊ីកាឡាតេច (Sika Latex) ជាមួយស៊ីម៉ង់ត៍ និងទឹក ដែលដើរតួនាទីជាភ្នាក់ងារបន្សីរវាងបាយអបូកថ្មីជាមួយជញ្ជាំងឥដ្ឋចាស់។ ក្រុមវិស្វករបានចាក់បេតុងអាមេជុំវិញគ្រោងទ្វារ និងបង្អួចទាំងអស់ ដោយយកប៉ុនកម្រាស់ជញ្ជាំង ៣០០មម x ១៣០ម.ម ចាក់បេតុងអាមេធ្នឹមក្រវ៉ាត់លើជញ្ជាំងដោយយកប៉ុនកម្រាស់ជញ្ជាំង។ ឈើគ្រឿងដំបូលត្រូវបានរុះរើចោលទាំងស្រុង ដោយភាគច្រើនមេស៊ី ពុកផុយ និងស្រួយហួតហែង ដែលមិនអាចប្រើប្រាស់វិញបានឡើយ។ នៅក្រោមកម្រាលមានបាញ់ថ្នាំការពារសត្វកណ្តៀរគ្រប់អគារទាំងអស់ ដែលថ្នាំនេះមានសុពលភាពរយៈពេល៥ឆ្នាំ។

ជាងនេះទៅទៀត ប្រព័ន្ធខ្សែភ្លើងមេ និងខ្សែអ៊ីនធើណែត ត្រូវបានដាក់បង្កប់ក្នុងដីទាំងអស់ ដោយអូសខ្សែមេភ្ជាប់ពីទូភ្លើង (ត្រង់ស្វូ) ទៅអគារនីមួយៗដោយឡែកពីគ្នា។ កម្រាលបង្កន់នៅតាមអគារត្រូវបានលាបស្រទាប់ការពារជម្រាបទឹក (Sika Top Seal 107 KH) និងដាក់ត្រាំទឹកចោលរយៈពេល ៣ថ្ងៃ មុននឹងចាប់ផ្តើមក្រាលការ៉ូបាត។ ក្រុមវិស្វករប្រើប្រាស់ការ៉ូខ្មែរ ដែលមានផ្កាក្បាច់គោមពេលផ្គុំគ្នាបួនស្លឹក មានការ៉ូផ្កាព័ទ្ធជុំវិញ និងការ៉ូពណ៌សព័ទ្ធពីខាងក្រៅ។





*សកម្មភាពតាមតំណាក់កាលនីមួយៗ នៃការជួយជុលអគារបេតិកភណ្ឌ*













សកម្មភាពតាមតំណាក់កាលនីមួយៗ នៃការជួយជុលអគារបេតិកភណ្ឌ

**អគារ M៖** អគារនេះមានកម្ពស់មួយជាន់ផ្ទាល់ដី ហើយរចនាបថនៃអគារនេះមានតែ២ទីតាំងគត់នៅក្នុងរាជធានីភ្នំពេញ ដែលមួយទៀតមានទីតាំងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងត្រូវបានសាងសង់ឡើងក្នុងពេលដំណាលគ្នា ក្នុងឆ្នាំ១៩១៤។ អគារនេះត្រូវបានប្រើប្រាស់ជាទីចាត់ការនាយកតាំងពីវិទ្យាស្ថានត្រូវបានបង្កើតឡើងដំបូងជាសាលាគរុកោសល្យនៅឆ្នាំ១៩៤១។




*មុនជួសជុល*




*ក្រោយជួសជុល*

**អគារ H៖** អគារនេះមានកម្ពស់២ជាន់ និងត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩១៤។ ជាន់ផ្ទាល់ដីគឺជាបន្ទប់ប្រជុំ VIP ដែលអាចដាក់អ្នកចូលរួមបានប្រមាណ៥០នាក់ និងអាចទទួលការប្រជុំតាមប្រព័ន្ធអនឡាញបាន ទាំងកម្រិតជាតិ តំបន់ និងអន្តរជាតិ។ ជាន់ទី១នៃអគារត្រូវបានប្រើប្រាស់ជាបន្ទប់ហាត់រៀនសិល្បៈ និងការសម្តែងសម។




*មុនជួសជុល*




*ក្រោយជួសជុល*

**អគារ G៖** អគារនេះមានកម្ពស់២ជាន់ និងត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩១៤ ហើយមានរចនាបថប្រហាក់ប្រហែលនឹងអគារ G ដែរ។ អគារនេះត្រូវបានប្រើប្រាស់ជាការិយាល័យធ្វើការរបស់អង្គភាពគ្រប់គ្រងកិច្ចការទូទៅរបស់វិទ្យាស្ថាន រួមទាំងការិយាល័យសិក្សា និងការិយាល័យរដ្ឋបាល។




*មុនជួសជុល*




*ក្រោយជួសជុល*

**អគារ A, B, C, D & E**៖ អគារបេតិកភណ្ឌទាំង៥នេះ ត្រូវបានសាងសង់ឡើងក្នុងពេលជាមួយគ្នា ក្នុងឆ្នាំ១៩១៤ ដែលមានតែមួយជាន់ផ្ទាល់ដី។ អគារ A, B, C, D ត្រូវបានប្រើប្រាស់ជាការិយាល័យធ្វើការរបស់អង្គភាពគ្រប់គ្រងកិច្ចការទូទៅ និងអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។ ដោយឡែកអគារ E ត្រូវបានប្រើប្រាស់ជាបន្ទប់សុខភាព ការិយាល័យធានាគុណភាពផ្ទៃក្នុង និងការិយាល័យព័ត៌មានវិទ្យា។



មុនជួសជុល



ក្រោយជួសជុល



មុនជួសជុល



ក្រោយជួសជុល



មុនជួសជុល



ក្រោយជួសជុល




*មុនជួសជុល*




*ក្រោយជួសជុល*



*អគារ E បន្ទាប់ពីជួសជុលរួច*

**អគារ** N៖ អគារនេះគឺជាអំណោយរបស់អង្គការ JICA ប្រចាំប្រទេសកម្ពុជា មានកម្ពស់២ជាន់ និងត្រូវបានសាងសង់ឡើងក្នុងឆ្នាំ២០០០។ អគារនេះត្រូវបានប្រើប្រាស់ជាបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ដែលរួមមាន៖ បន្ទប់ពិសោធន៍មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដី-បរិស្ថានវិទ្យា។




*មុនជួសជុល*




*ក្រោយជួសជុល*

## មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

### ១. សាវតារ

មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី គឺជាអង្គភាពស្វយ័តមួយដែលមានទីតាំងស្ថិតក្នុងអគារ «I» នៃវិទ្យាស្ថានជាតិអប់រំ។ អគារមជ្ឈមណ្ឌលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៩ តាមប្រកាសលេខ១៧៩៩ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ និងដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ មជ្ឈមណ្ឌលត្រូវបានផ្តល់សិទ្ធិដោយក្រសួងអប់រំ យុវជន និង កីឡា ក្នុងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ អប់រំឯកទេសប្រឹក្សាគរុកោសល្យ (វគ្គពន្លឿនរយៈពេល១ឆ្នាំ) តាមរយៈប្រកាសលេខ១៤៦៦ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ដើម្បីជួយដល់ការពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីដែលជាសាលារៀនរដ្ឋស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ពីរាជរដ្ឋាភិបាល និងទាមទារឱ្យមានគ្រូបង្រៀនដែលមានស្តង់ដាវិជ្ជាជីវៈខ្ពស់បម្រើការងារនៅទីនោះ។ ទន្ទឹមគ្នានោះ មជ្ឈមណ្ឌលក៏បានផ្តល់ជូនគ្រូប្រឹក្សាគរុកោសល្យ ដើម្បីគាំទ្រដល់សាលាធនធាន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននាពេលកន្លងមក និងមានផែនការគាំទ្រដល់សាលារៀនជាប់ស្តង់ដា សាលាគំរូ សាលាអប់រំស្នែម និងសាលារៀនដែលមានតម្រូវការ។

### ២. គោលបំណងសំខាន់ៗ

១.ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់កម្មវិធីសាលារៀនជំនាន់ថ្មីមួយ ដែលផ្តល់ជូននូវបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ

២.ជ្រើសរើសបេក្ខជនដែលមានសមត្ថភាពសម្រាប់ការបណ្តុះបណ្តាលដែលមានគុណភាពខ្ពស់អាចទ្រទ្រង់ការរៀនសូត្រនៅក្នុងថ្នាក់រៀនតាមបែបសតវត្សរ៍ទី២១

៣.បង្កើតប្រព័ន្ធប្រឹក្សាគរុកោសល្យគ្រូបង្រៀនដោយជោគជ័យ ដែលប្រើបច្ចេកវិទ្យាដើម្បីជំរុញការអភិវឌ្ឍជំនាញវិជ្ជាជីវៈ សម្រាប់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី សាលាធនធាន សាលាជាប់ស្តង់ដា សាលាគំរូ សាលាអប់រំស្នែម និងសាលារៀនដែលមានតម្រូវការជាបន្តបន្ទាប់។



*អគារ I មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី*

**អគារ«ក»**៖ ជាអគារអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវបានសាងសង់ឡើងក្នុងឆ្នាំ១៩១៤ មានកម្ពស់ពីរជាន់ និងមានរចនាបថបារាំង។ ក្នុងសម័យសង្គមរាស្រ្តនិយម អគារនេះត្រូវបានប្រើប្រាស់ជាទីចាត់ការ សាកលវិទ្យាធិការ **សាស្រ្តាចារ្យ ភឹង តុន** ដែលជាសាកលវិទ្យាធិការទី១ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ នៅឆ្នាំ២០២៤ ក្រោយពីជួសជុលកែលម្អរួច ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចប្រែក្លាយ អគារទៅជាអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។



*អគារ ក មើលចំពីមុខ*



*អគារ ក មើលពីជ្រុងខាងត្បូង*



*អគារ ក មើលពីជ្រុងខាងក្រោយ*



*អគារ ក មើលពីជ្រុងខាងជើង*



*រូបក្នុងអគារ*



*រូបក្នុងអគារ*

**វិទ្យាល័យអនុវត្ត៖** អគារនេះត្រូវបានសាងសង់ឡើងក្នុងរបបសាធារណរដ្ឋខ្មែរ។ មានកម្ពស់២ជាន់ស្មើនឹង៨បន្ទប់ អគារនេះត្រូវបានប្រើប្រាស់ជាថ្នាក់រៀនរបស់វិទ្យាល័យអនុវត្តនៃវិទ្យាស្ថានជាតិអប់រំ។ បន្ទប់ចំនួន២ ត្រូវបានប្រែក្លាយជាបណ្ណាល័យសតវត្សរ៍ទី២១ ដែលមានផ្ទុកសៀវភៅ សម្រាប់សិស្សអាន និងធ្វើសកម្មភាពក្រៅម៉ោងសិក្សាបន្ថែម។ គ្រប់បន្ទប់រៀនទាំងអស់សុទ្ធតែមានបំពាក់ថ្នាក់រៀនវៃឆ្លាត។



*អគារអនុវិទ្យាល័យ*



*បន្ទប់សិក្សា*



*ទីចាត់ការ*

**បឋមសិក្សាអនុវត្ត៖** អគារនេះត្រូវបានសាងសង់ឡើងក្នុងរបបសាធារណរដ្ឋខ្មែរ។ មានកម្ពស់៣ជាន់ស្មើនឹង១៥បន្ទប់ អគារនេះត្រូវបានប្រើប្រាស់ជាទីចាត់ការ និងថ្នាក់រៀនរបស់បឋមសិក្សាអនុវត្ត។ បន្ទប់ចំនួន២ ត្រូវបានប្រែក្លាយជាបណ្ណាល័យសតវត្សរ៍ទី២១ ដែលមានផ្ទុកសៀវភៅសម្រាប់កុមារអាន និងធ្វើសកម្មភាពក្រៅម៉ោងសិក្សាបន្ថែម។ គ្រប់បន្ទប់រៀនទាំងអស់សុទ្ធតែមានបំពាក់ថ្នាក់រៀនវៃឆ្លាត។



*ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សម្ពោធបឋមសិក្សាអនុវត្ត*



*សកម្មភាពថ្នាក់រៀន*



*បណ្ណាល័យ*



*កន្លែងលេងកម្សាន្ត*



*សកម្មភាពសិស្សនៅខាងមុខសាលា*

**អគារសាលប្រជុំសម្តេច៖** សាលវប្បធម៌សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ត្រូវបានសាងសង់ឡើងក្នុងឆ្នាំ២០១៣ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងលោកជំទាវ។ អគារនេះគឺជាសាលពហុបំណងដែលបម្រើឱ្យការជួបជុំទ្រង់ទ្រាយធំ ដែលអាចដាក់អ្នកចូលរួមបានប្រមាណ១២០០នាក់។ សាលប្រជុំនេះក៏ត្រូវបានប្រើប្រាស់ សម្រាប់ការបណ្តុះបណ្តាល ការប្រជុំ ពិធីចែកសញ្ញាបត្រ ការសម្តែងសិល្បៈ និងកម្មវិធីជួបជុំផ្សេងៗទៀត។ អគារនេះត្រូវបានជួសជុលកែលម្អឡើងវិញទាំងស្រុង ដោយបានបន្ថែមទ្វារចូលទាំងសងខាងចំនួន៤ដែលបំពាក់នូវខ្លោងទ្វារ ចម្លងចេញពីរចនាបថប្រាសាទបន្ទាយស្រី។



*សាលប្រជុំសម្តេច*


*រូបភាពខាងក្នុងសាលប្រជុំ*

**អគារ B07៖** អគារនេះត្រូវបានសាងសង់ឡើងនៅឆ្នាំ២០០៧ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន។ អគារនេះមានកម្ពស់៤ជាន់ និង៤៤បន្ទប់។ បន្ទាប់ពីជួសជុលកែលម្អរួចរាល់នៅចុងឆ្នាំ២០២៤ អគារនេះត្រូវបានប្រើប្រាស់ជាការិយាល័យរបស់សាលាក្រោយបរិញ្ញាបត្រ និងថ្នាក់រៀនក្រោយបរិញ្ញាបត្រ ដែលគ្រប់បន្ទប់ទាំងអស់សុទ្ធបានបំពាក់ថ្នាក់រៀនវៃឆ្លាត។



*អគារ B-07 ទីវិទ្យាស្ថានជាតិអប់រំមាន៤ជាន់ ៤៤បន្ទប់*


*គរុនិស្សិតកំពុងសិក្សា*

## ៤. ការសាងសង់របង ខ្លោងទ្វារ និងខឿនព័ទ្ធជុំវិញ

**ខ្លោងទ្វារខាងត្បូង៖** ខ្លោងទ្វារខាងត្បូង គឺជាខ្លោងទ្វារធំសម្រាប់ការចេញចូលទូទៅ។ រចនាបថរបស់ខ្លោងទ្វារនេះមានទម្រង់ជាសៀវភៅបើក ដែលតំណាងឱ្យការអប់រំ និងការបណ្ដុះបណ្ដាល។ បន្ថែមលើនេះ ខ្លោងទ្វារក៏មានចម្លងរចនាបថប្រសាទអង្គរវត្ត និងប្រក់ក្បឿងក្បាច់ខ្មែរ រួមទាំងផ្ទាំងពីរដើមសងខាង និងរងទឹកក្បាច់គ្របកឈូកសម័យអង្គ។ នៅខាងស្ដាំមានផ្លាក់និមិត្តរូបវិទ្យាស្ថានជាតិអប់រំ ហើយនៅខាងឆ្វេងមានផ្លាក់គុណតម្លៃទាំង៥ របស់វិទ្យាស្ថាន៖ ឧត្តមភាព គុណភាព សមធម៌ សុចរិត នវានុវត្តន៍។ ឈរនៅទល់មុខវត្តលង្កាព្រះកុសុមារាម ខ្លោងទ្វារនេះតំណាងឱ្យគុណតម្លៃនៃការបណ្ដុះបណ្ដាលគ្រូបង្រៀន សីលធម៌ និងវិជ្ជាជីវៈគ្រូបង្រៀន។




*ខ្លោងទ្វារខាងត្បូង*



*ខ្លោងទ្វារខាងត្បូងមើលពីចម្ងាយ*

**ដងទង់ជាតិ៖** ដងទង់ជាតិត្រូវបានសាងសង់ឡើងជាថ្មី ដោយស្ថិតនៅចំកណ្តាលនៃបរិវេណវិទ្យាស្ថាន។ រចនាបថខឿនដងទង់ជាតិ ត្រូវបានចម្លងចេញពីខឿនវិមានឯករាជ្យ។ ទីតាំងនេះគឺជាកន្លែងដែលគណៈគ្រប់គ្រង បុគ្គលិកអប់រំ គ្រូឧទ្ទេស និងគរុនិស្សិតទាំងអស់ ជួបជុំគ្នានៅរៀងរាល់ព្រឹកថ្ងៃចន្ទ និងល្ងាចថ្ងៃសុក្រ ដើម្បីគោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ទីតាំងនេះក៏ជាកន្លែងជួបជុំប្រារព្ធពិធីបុណ្យជាតិដូចជាបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ រួមទាំងការលេងល្បែងប្រជាប្រិយ របស់បុគ្គលិកអប់រំ និងគរុនិស្សិតផងដែរ។



*ទិដ្ឋភាពគរុនិស្សិត និងសិស្សវិទ្យាល័យអនុវត្តគោរពទង់ជាតិ*

**បរិស្ថានជុំវិញ៖** ដើម្បីលើកកម្ពស់បរិស្ថានសិក្សា និងសោភណ្ឌភាពខាងក្រៅ របងព័ទ្ធជុំវិញប្រវែង៦៤២ម៉ែត្រ និងខឿនព័ទ្ធជុំវិញដែលមានទំហំ២៥០០ម៉ែត្រការ៉េ ត្រូវបានសាងសង់ឡើងវិញ និងបញ្ចប់ទាំងស្រុងនៅខែមីនា ឆ្នាំ២០២៤ ដោយរក្សានៅរចនាបថដើម និងដើមឈើទាំងអស់នៅលើខឿន។ ក្រៅពីខ្លោងទ្វារធំ និងខ្លោងទ្វារចូលបណ្ណាល័យនៅទិសខាងត្បូង វិទ្យាស្ថានមានច្រកចូលចំនួន៤ទៀត៖ ច្រកចូល២ នៅទិសខាងកើត ១នៅទិសខាងជើង និង១ទៀតនៅទិសខាងលិច។ ដោយក្រាលការ៉ូឡាថ្មភ្នំ ខឿនព័ទ្ធជុំវិញវិទ្យាស្ថាន បានក្លាយទៅជាកន្លែងដើរហាត់ប្រាណសម្រាប់សុខភាពដ៏ល្អ របស់សាធារណជន។



*របងខាងត្បូងវិទ្យាស្ថានជាតិអប់រំ*



ខឿនជុំវិញវិទ្យាស្ថាន



ច្រកទ្វារខាងកើតទី១



ច្រកទ្វារខាងកើតទី២




ច្រកទ្វារខាងជើង

## ៥. ការរៀបចំសួនច្បារ ទីលានកីឡា ចំណតយានជំនិះ អាហារដ្ឋាន

**ការរៀបចំបរិស្ថានខាងក្នុង និងសួនច្បារ៖** សួនច្បារចំនួន១០កន្លែង ត្រូវបានរៀបចំឡើង ដោយមានដាំផ្កាខ្មែរ និងដើមឈើខ្មែរកម្រ៖ អូញម៉ូញ ភ្នៅ ចារ ក្រញូង នាងនួន បេង ធ្នង់ ជម្ពូទេព រំដួល ដកសោក បំពេញរាជ ពង្រ ស្រម៉ សម្រង ចំបក់ ជ្រេស ស្រឡៅ សុក្រំ។ល។ រូបសញ្ញាវិទ្យាស្ថានជាតិអប់រំឆ្លាក់ពីថ្មភ្នំ អមដោយក្បាលនាគរចនាបថអង្គចំនួន ២ ត្រូវបានដាក់នៅចន្លោះអគារ A និង B។ នៅខាងក្រោយអគារ M មានរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ និងដើមពោធិ៍មួយដើមដែលមានអាយុជិត១០០ឆ្នាំ។ ក្រៅពីនេះ មានទីលានបាល់បោះមួយកន្លែង និងកន្លែងចតយានជំនិះមួយកន្លែង។






*រូបសញ្ញាវិទ្យាស្ថានជាតិអប់រំ*



*កញ្ចុះអង្គុយលេងសម្រាប់សិស្ស និស្សិត*



ទីធ្លាកីឡា



បង្គន់អនាម័យសាធារណៈ



ចំណតរថយន្តក្រោមដី



ចំណតកង់ ម៉ូតូ នៅខាងក្រោយវិទ្យាល័យអនុវត្ត



អាហារដ្ឋាន



ម៉ាស៊ីនទឹកចម្រោះទឹកស្អាត



សួនច្បារខាងត្បូង



អំពូលសូឡាសម្រាប់បំភ្លឺពេលរាត្រី

## ៦. ការរៀបចំប្រព័ន្ធផ្លូវ ភ្លើង ទឹក លូ សុវត្ថិភាព និងបច្ចេកវិទ្យា

ដើម្បីសុវត្ថិភាព សោភណ្ឌភាព និងបរិស្ថាន នៅក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ប្រព័ន្ធផ្លូវ ប្រព័ន្ធភ្លើង ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធសុវត្ថិភាព និងប្រព័ន្ធបច្ចេកវិទ្យា ត្រូវបានរុះរើ និងកែលម្អឡើងវិញទាំងស្រុង។ ផ្លូវចំនួន៨ខ្សែ ត្រូវបានរៀបចំឡើងវិញទាំងស្រុង ដោយចាក់បេតុង និងអ៊ុតកៅស៊ូពីលើ ដោយមានទាំងការគូសបន្ទាត់ចរាចរណ៍ និងបន្ទាត់សម្រាប់រត់ម៉ារ៉ាតុង រួមចំណែកដល់ការលើកកម្ពស់កីឡា និងសុខភាពរបស់មន្ត្រី គរុនិស្សិត និងសហគមន៍របស់វិទ្យាស្ថានទាំងមូល។



*ផ្លូវក្នុងវិទ្យាស្ថានដែលមានគំនូសចរាចរណ៍*



*ជម្រាលជនមានពិការភាព*



*បណ្ដាញលូ*

វិទ្យាស្ថានបានរៀបចំប្រព័ន្ធទឹក និងប្រព័ន្ធលូឡើងវិញ ដើម្បីធានាថា អគារទាំងអស់មានទឹកប្រើប្រាស់គ្រប់គ្រាន់ចេញលឿន និងមានប្រព័ន្ធលូ ដែលមានមុខកាត់ ៨០មម ដែលអាចរំដោះទឹកភ្លៀង មិនឱ្យមានការលិចបរិវេណវិទ្យាស្ថានក្នុងរដូវវស្សា។




*ប្រព័ន្ធសុវត្ថិភាព*



*បន្ទប់ Server*

ប្រព័ន្ធសុវត្ថិភាព និងប្រព័ន្ធបច្ចេកវិទ្យា ត្រូវបានរៀបចំបំពាក់ឡើងវិញទាំងស្រុង ដោយធានាថាបរិវេណទាំងមូល មានកាមេរ៉ាសុវត្ថិភាព និងអ៊ីនធឺណែតប្រើប្រាស់គ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការអនុវត្តការងារប្រចាំថ្ងៃផង និងគាំទ្រដល់ការរៀន និងបង្រៀនក្នុងបរិបទឌីជីថលផង។



*បន្ទប់សុខភាព*



*បន្ទប់សុខភាព*

ប្រព័ន្ធភ្លើងទាំងអស់រត់ក្រោមដី ពីអគារមួយទៅអគារមួយទៀត និងមានរីហ្គាសម្រាប់ត្រួតពិនិត្យនិងជួសជុលនៅពេលក្រោយៗទៀត។ ប្រព័ន្ធខ្សែមេ គឺរត់សម្រាប់តែអគារនីមួយៗដាច់ដោយឡែកពីគ្នា តភ្ជាប់ពីប្រអប់ភ្លើងមេនៅជិតត្រង់ស្វូភ្ជាប់ទៅប្រអប់មេក្នុងអគារនីមួយៗ។ ត្រង់ស្វ័រធំមួយដែលមានកម្លាំង ១២៥០ KVA ត្រូវបានបំពាក់ថ្មីស្រឡាង ដើម្បីធានាការផ្គត់ផ្គង់ភ្លើងប្រើប្រាស់ឱ្យបានគ្រប់គ្រាន់។



*ត្រង់ស្វូ-1250KVA cooper type*



*ការភ្ជាប់ខ្សែបណ្ដាញមេទៅប្រអប់ភ្លើងមេ-ACB Pannel*



*ទីធ្លាក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ*

ជំពូក
៣

# ការបណ្តុះបណ្តាលដំបូង

មហាវិទ្យាល័យគរុកោសល្យនៃវិទ្យាស្ថានជាតិអប់រំ បានកំពុងដើរតួនាទីស្នូលនៅក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលដំបូង ជាពិសេសការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញាបត្រ+២។ យោងតាមអនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ មហាវិទ្យាល័យគរុកោសល្យមានដេប៉ាតឺម៉ង់ចំនួន៣ គឺ៖

១. ដេប៉ាតឺម៉ង់អប់រំវិទ្យាសាស្ត្រគណិតវិទ្យា បច្ចេកវិទ្យាព័ត៌មាន និងអប់របច្ចេកទេស
២. ដេប៉ាតឺម៉ង់អប់រំវិទ្យាសាស្ត្រសង្គម សិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
៣. ដេប៉ាតឺម៉ង់ចិត្ត-គរុកោសល្យ និងសិក្សាអប់រំ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួនក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម មហាវិទ្យាល័យគរុកោសល្យមានតួនាទីជាសេនាធិការឱ្យវិទ្យាស្ថានជាតិអប់រំលើការគ្រប់គ្រង និងដឹកនាំដេប៉ាតឺម៉ង់ចំណុះ សម្របសម្រួលអភិវឌ្ឍការបណ្តុះបណ្តាល និងអនុវត្តកម្មវិធីសិក្សាជំនាញនានាចំណុះឱ្យមហាវិទ្យាល័យ។ មហាវិទ្យាល័យមានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តមឯកទេសផ្សេងៗ និងគ្រូបង្រៀនកម្រិតមូលដ្ឋានឯកទេសភាសាបារាំងតាមរូបភាពអាហារូបករណ៍ និងការបង់ថ្លៃសិក្សា
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដំបូងឱ្យឆ្លើយតប ទៅនឹងតម្រូវការសេដ្ឋកិច្ច សង្គមពុទ្ធិ និងវិបុលភាព
- រៀបចំផែនការអភិវឌ្ឍន៍មហាវិទ្យាល័យគរុកោសល្យស្របតាមផែនការយុទ្ធសាស្ត្ររបស់របស់វិទ្យាស្ថានជាតិអប់រំ
- គ្រប់គ្រងការរៀន ការបង្រៀន ការស្រាវជ្រាវ និងវិធីសាស្ត្របង្រៀន
- រៀបចំ និងអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូឧទ្ទេស
- កសាងបណ្តាញទំនាក់ទំនងជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស តំបន់ និងលើសាកលលោក។

## ១. ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញាបត្រ+២ ត្រូវបានបង្កើតឡើងដោយផ្អែកលើទស្សនវិជ្ជាអប់រំ ភាពជឿជាក់ ការតម្រង់ទិស ទ្រឹស្តីនៃការរៀននិងបង្រៀន និងតម្រូវការសង្គមនាយុគសម័យឌីជីថល តាមរយៈទស្សនវិជ្ជាអប់រំបែបរីកចម្រើន និងទស្សនវិជ្ជាអប់រំបែបស្ថាបនានិយម ដោយជឿជាក់ថាកម្មវិធីបណ្តុះបណ្តាលពហុមុខវិជ្ជានេះ នឹងផ្តោតការយកចិត្តទុកដាក់ទៅលើជំនាញទូទៅនៅដំណាក់កាលដំបូង បំណិន និងការងារប្រតិបត្តិវិជ្ជាជីវៈនៅក្នុងដំណាក់កាលបន្ត។ កម្មវិធីបណ្តុះបណ្តាលនេះ បំពាក់មូលដ្ឋានគ្រឹះទាំងខាងផ្នែកបញ្ញត្តិ និងទ្រឹស្តីរឹងមាំ ដល់អ្នកសិក្សាឱ្យមានឱកាសគ្រប់គ្រាន់ ដើម្បីយកចំណេះដឹង និងបំណិនទាំងនោះ ទៅប្រើប្រាស់ក្នុងលក្ខខណ្ឌការងារជាក់ស្តែង។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវបានរំពឹងថានឹងបណ្តុះភាពចង់ចេះចង់ដឹងរបស់អ្នកសិក្សា និងជំរុញឱ្យពួកគេ មានការគិតកម្រិតខ្ពស់ និងការកសាងចំណេះដឹង តាមរយៈសកម្មភាពសិក្សាក្រៅម៉ោងសិក្សា ក្លិបសិក្សា កិច្ចការគម្រោង ការធ្វើពិសោធន៍វិទ្យាសាស្ត្រ និងការស្រាវជ្រាវជាក់ស្តែង ដើម្បីចូលរួមដោះស្រាយបញ្ហានានាក្នុងសង្គម និងនាំមកនូវការផ្លាស់ប្តូរប្រកបដោយភាពស្ថាបនា។ ហេតុដូច្នេះ កម្មវិធីបណ្តុះ បណ្តាលគ្រូបង្រៀនកម្រិតឧត្តមពិតជាមានសារៈសំខាន់ សម្រាប់

អភិវឌ្ឍន៍គ្រូបង្រៀនឱ្យបានគ្រប់ជ្រុងជ្រោយទាំងរាងកាយ បញ្ញាញាណ អារម្មណ៍ និងស្មារតី ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គមចំណេះដឹងប្រកបដោយនិរន្តរភាព ភាពសុខដុមរមនា និងសន្តិភាព។

កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) មានគោលបំណងបណ្តុះបណ្តាល អ្នកសិក្សាឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តមប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ និងអ្នកស្រាវជ្រាវអប់រំដែលមានការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ នៅពេលបញ្ចប់ការបណ្តុះបណ្តាល គរុនិស្សិតកម្រិតឧត្តម(បរិញ្ញាបត្រ+២) នឹងទទួលបាននូវ (១) ចំណេះដឹង (២) ជំនាញនៃការគិតវិភាគ (៣) ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការ ទទួលខុសត្រូវ (៤) ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង និង(៥)ជំនាញចិត្តចលនា។

គរុនិស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ នឹងទទួលបានសញ្ញាបត្រ «បរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម»។

ដើម្បីសម្រេចបាននូវគោលដៅបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំដូចបានកំណត់ក្នុងក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញាបត្រ+២ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បញ្ចប់ការសិក្សាចំនួន៤៨ក្រេឌីត ដោយរាប់បញ្ចូលទាំងការសរសេរនិក្ខេបបទ
- ចុះធ្វើកម្មសិក្សាគរុកោសល្យ (កម្មសិក្សាសង្កេត កម្មសិក្សា ពាក់កណ្តាលប្រតិបត្តិ និងកម្មសិក្សាប្រតិបត្តិគរុកោសល្យ)
- អនុវត្តសកម្មភាពក្រៅម៉ោងសិក្សាដូចបានកំណត់ក្នុងក្របខណ្ឌកម្មវិធីបណ្តុះបណ្តាល រួមមានក្លិបសិក្សា ការងារគម្រោង ការស្រាវជ្រាវ ស្វ័យសិក្សា ការធ្វើពិសោធន៍ និងការតាំងពិព័រណ៍អប់រំ

ឯកសារសំខាន់សម្រាប់គាំទ្រការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+២)













ស្ថិតិគរុនិស្សិតកម្រិតឧត្តម (បរិញ្ញាបត្រ+១) និង (បរិញ្ញាបត្រ +២) ដែលទទួលបានការបណ្តុះបណ្តាល តាមជំនាន់នីមួយៗនៅវិទ្យាស្ថានជាតិអប់រំ

គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+១)

| ជំនាន់ | ឆ្នាំសិក្សា | សរុប | ស្រី |
|---|---|---|---|
| ១ | ១៩៩៥-១៩៩៦ | ១១២៩ | ២២៩ |
| ២ | ១៩៩៧-១៩៩៦ | ៩៦១ | ១៩៥ |
| ៣ | ១៩៩៧-១៩៩៨ | ១១២៥ | ២៥០ |
| ៤ | ១៩៩៨-១៩៩៩ | ២៦៨ | ៣៤ |
| ៥ | ១៩៩៩-២០០០ | ៣៤៩ | ៦៥ |
| ៦ | ២០០០-២០០១ | ២៤៩ | ៨១ |
| ៧ | ២០០១-២០០២ | ២៤៣ | ៨០ |
| ៨ | ២០០២-២០០៣ | ៣១៨ | ៩២ |
| ៩ | ២០០៣-២០០៤ | ៣៣១ | ៨១ |
| ១០ | ២០០៤-២០០៥ | ៣៥៩ | ៩១ |
| ១១ | ២០០៥-២០០៦ | ៤៩០ | ១១៩ |
| ១២ | ២០០៦-២០០៧ | ៥៣១ | ១៤៨ |
| ១៣ | ២០០៧-២០០៨ | ៤៨៨ | ១៣០ |
| ១៤ | ២០០៨-២០០៩ | ៤៨៩ | ១២៩ |
| ១៥ | ២០០៩-២០១០ | ៦៩៥ | ២២៥ |
| ១៦ | ២០១០-២០១១ | ៩៦៩ | ៣៣៧ |

គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

| ជំនាន់ | ឆ្នាំសិក្សា | សរុប | ស្រី |
|---|---|---|---|
| ១ | ២០២១-២០២៣ | ៩៨ | ៤៨ |
| ២ | ២០២៣-២០២៥ | ៩៨ | ៤៨ |
| សរុប | | ៨៦០ | ៤១៤ |

| | | | |
|---|---|---|---|
| ១៧ | ២០១១-២០១២ | ៩៩៥ | ២៨០ |
| ១៨ | ២០១២-២០១៣ | ៩៨០ | ៣០២ |
| ១៩ | ២០១៣-២០១៤ | ៩៩៨ | ៣៤៤ |
| ២០ | ២០១៤-២០១៥ | ១១៨៣ | ៤១៨ |
| ២១ | ២០១៥-២០១៦ | ៨៧១ | ៣៤០ |
| ២២ | ២០១៦-២០១៧ | ៨៥០ | ៣៣៧ |
| ២៣ | ២០១៧-២០១៨ | ៨០៥ | ៣២៤ |
| ២៤ | ២០១៨-២០១៩ | ៨៤៦ | ៣៩៣ |
| ២៥ | ២០១៩-២០២០ | ៩៩៤ | ៤៥៨ |
| No | ២០២០-២០២១ | ០ | ០ |
| ២៦ | ២០២១-២០២២ | ១០១១ | ៤៧៩ |
| សរុប | ២០២១-២០២២ | ១៨៥២៧ | ៥៩៥៧ |

បណ្តុំមុខវិជ្ជា និងចំនួនក្រេឌីតតាមប្រភេទនៃការបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

| **ល.រ** | **ក្រុមមុខវិជ្ជា** | **ចំនួនក្រេឌីត** |
|---|---|---|
| ១ | ២០១២-២០១៣ | ១៧ |
| ២ | ២០១៣-២០១៤ | ១៥ |
| ៣ | ២០១៤-២០១៥ | ៦ |
| ៤ | ២០១៥-២០១៦ | ៤ |
| ៥ | ២០១៦-២០១៧ | ៦ |
| | សរុប | ៤៨ |

មុខវិជ្ជាឯកទេសទាំង១៩ សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) រួមមាន៖

១. អក្សរសាស្ត្រខ្មែរ
២. ភាសាអង់គ្លេស
៣. គណិតវិទ្យា
៤. រូបវិទ្យា
៥. គីមីវិទ្យា
៦. ជីវវិទ្យា
៧. ផែនដីវិទ្យា
៨. សីលធម៌ពលរដ្ឋ
៩. ប្រវត្តិវិទ្យា
១០. ភូមិវិទ្យា
១១. សេដ្ឋកិច្ច
១២. ព័ត៌មានវិទ្យា
១៣. វិស្វកម្មកុំព្យូទ័រ
១៤. អគ្គិសនី
១៥. អេឡិចត្រូនិក
១៦. មេកានិក
១៧. បសុវប្បកម្ម
១៨. ក្សេត្រសាស្ត្រ
១៩. កែច្នៃអាហារ

## ២. សកម្មភាពក្រៅម៉ោងសិក្សា

សម្រាប់ម៉ោងដែលនៅសេសសល់ពីការរៀននៅក្នុងថ្នាក់គរុ-និស្សិតត្រូវធ្វើការងារមួយចំនួនទៀត ដើម្បីបង្គ្រប់លក្ខខណ្ឌនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមរួមមាន៖ ក្លឹបសិក្សា ការតាំងពិព័រណ៍ ការអប់រំស្វែមនិងពិសោធន៍វិទ្យាសាស្ត្រ ការប្រើប្រាស់បណ្ណាល័យ សុខភាពសិក្សា កិច្ចការគម្រោង កិច្ចការស្រាវជ្រាវ ការសរសេរកិច្ចតែងការបង្រៀន ការថតឃ្លីបវីដេអូពីសកម្មភាពនៃការបង្រៀនរបស់គរុនិស្សិត និងការចុះហ្វឹកហាត់ការបង្រៀនតាមវិទ្យាល័យអនុវត្ត និងវិទ្យាល័យសហការ លើការអនុវត្តស្តង់ដាសាលារៀនគំរូ។



### ក្លឹបសិក្សា

ដើម្បីជួយគាំទ្រដល់គរុនិស្សិតកម្រិតឧត្តម វិទ្យាស្ថានជាតិអប់រំបានបង្កើតក្លឹបសិក្សាតាមឯកទេសទាំង១៩មុខវិជ្ជា ដោយផ្តោតការស្រាវជ្រាវលើ៥បណ្តុំ ស្មើនឹង១១៣ប្រធាន-បទ និងក្លឹបសិក្សាបន្ថែមមានចំនួន១០ក្លឹប ដោយផ្តោតលើ៖ ក្លឹបស្រាវជ្រាវលើមុខវិជ្ជាឯកទេស វិធីសាស្ត្របង្រៀន ការផលិតសម្ភារឧបទេស ក្លឹបជជែកដេញដោល ក្លឹបសិល្បៈ (ភ្លេង របាំ ចម្រៀង) ក្លឹបកីឡា ក្លឹបភាសាបរទេស និងក្លឹបពិធីករ។ គរុនិស្សិតនឹងចែករំលែកពីគំនិតច្នៃប្រឌិត ដែលទទួលបានពីការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងណែនាំតាមសាលារៀន ដើម្បីរៀបចំក្លឹបសិក្សាមួយចំនួន ដូចជាក្លឹបសិក្សាតាមមុខវិជ្ជា ក្លឹបភាសាបរទេស ក្លឹបព័ត៌មានវិទ្យា និងក្លឹបជជែកដេញដោលជាដើម។ ក្លឹបសិក្សាជាសកម្មភាពក្រៅម៉ោងសិក្សាដោយផ្សារភ្ជាប់ចំណេះដឹងទៅនឹងខ្លឹមសារមេរៀន និងជាមួយកិច្ចការគម្រោងដើម្បីឆ្លើយតបទៅនឹងការប្រតិបត្តិវិជ្ជាជីវៈនៃស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។

ក្លឹបសិក្សាស្នូល ដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០២៤ មានដូចក្នុងតារាងខាងក្រោម៖

| ប្រធានបទ | ចំនួន | ផ្សេងៗ |
|---|---|---|
| បណ្ដុំទី១៖ ការសរសេរសៀវភៅសិក្សាគោល | ២៤ | |
| បណ្ដុំទី២៖ ការសរសេរសៀវភៅកិច្ចតែងការបង្រៀន ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបស្ថាបនានិយម | ១៨ | |
| បណ្ដុំទី៣៖ ការផលិតសម្ភារៈឧបទ្ទេស | ១៩ | |
| បណ្ដុំទី៤៖ ការសរសេរសៀវភៅសំណួរ និងលំហាត់ (តាមកម្រិតប្លូម) | ២៣ | |
| បណ្ដុំទី៥៖ ការស្រាវជ្រាវថ្មី និងនវានុវត្តន៍ | ២៩ | |
| សរុប | ១១៣ | |

ក្លឹបសិក្សាបន្ថែម ដែលជាផ្នែកមួយនៃសកម្មភាពក្រៅម៉ោងសិក្សា មានដូចក្នុងតារាងខាងក្រោម៖

| ប្រភេទក្លឹប | ចំនួន | សមាជិក | ផ្សេងៗ |
|---|---|---|---|
| ១. ក្លឹបភាសាអង់គ្លេស | ៣ កម្រិត | ២០៤ នាក់ | កម្រិតដំបូង ៨៩នាក់ |
| ១៩ | ២០១៣-២០១៤ | ៩៩៨ | កម្រិតមធ្យម ៨២នាក់<br>កម្រិតខ្ពស់ ៣៣នាក់ |
| ២. ក្លឹបភាសាបារាំង | ១ កម្រិត | ៥២ នាក់ | |
| ៣. ក្លឹបភាសាថៃ | ១ កម្រិត | ៤៨ នាក់ | |
| ៤. ក្លឹបភាសាចិន | ១ កម្រិត | ៤៦ នាក់ | |
| ៥. ក្លឹបពិធីករ | ១ ក្រុម | ៣៦ នាក់ | |
| ៦. ក្លឹបរបាំ (ប្រពៃណី និងបុរាណ) | ២ ក្រុម | ៤០ នាក់ | |
| ៧. ក្លឹបចម្រៀង (មហោរី និងភ្លេងការ) | ២ ក្រុម | ២២ នាក់ | |
| ៨. ក្លឹបឧបករណ៍តន្ត្រី (ខ្លុយ និងទ្រ) | ២ ក្រុម | ១៤ នាក់ | |
| ៩. ក្លឹបកីឡា បាល់ទាត់ | ១ ក្រុម | ១៨ នាក់ | |
| ១០. ក្លឹបកីឡា បាល់ទះ | ១ ក្រុម | ១២ នាក់ | |
| សរុប | ២៩ ក្លឹប | | |

## ការតាំងពិព័រណ៍អប់រំ

ក្នុងមួយឆ្នាំសិក្សា គរុនិស្សិតត្រូវរៀបចំការតាំងពិព័រណ៍អប់រំចំនួន២ដង ដោយផ្ដោតលើវិធីសាស្ត្របង្រៀន ការផលិតសម្ភារឧបទេស កិច្ចតែងការបង្រៀន ការសរសេរសៀវភៅជំនួយស្មារតី និងឧបករណ៍នវានុវត្តន៍។ គរុនិស្សិតនឹងចែករំលែកគំនិតច្នៃប្រឌិត ដែលទទួលបានពីការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ ដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងណែនាំសិស្សនៅតាមសាលា ក្នុងការរៀបចំពិព័រណ៍ស្នាដៃនៅចុងឆ្នាំសិក្សា។ ស្នាដៃតាំងពិព័រណ៍ កើតចេញពីក្លឹបសិក្សា និងការងារគម្រោង តាមរយៈគំនិតច្នៃប្រឌិតប្រកបដោយទេពកោសល្យ និងនិន្នាការនៃការអប់រំ។




*គ្រូឧទ្ទេសមុខវិជ្ជាសិល្បៈជាមួយគរុនិស្សិតក្នុងកម្មវិធីពិព័រណ៍អប់រំ*

## ការអប់រំស្នែម និងពិសោធន៍វិទ្យាសាស្ត្រ

វិទ្យាស្ថានជាតិអប់រំកសាងឯកសារគាំទ្រមួយចំនួនរួមមាន សៀវភៅណែនាំស្ដីការអប់រំស្នែម សៀវភៅរៀន និងបង្រៀនស្នែម សៀវភៅណែនាំស្ដីពីពិសោធន៍វិទ្យាសាស្ត្រ សៀវភៅគ្រប់គ្រងបន្ទប់ពិសោធន៍និងប្រើប្រាស់សម្ភារពិសោធន៍ សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ និងផលិតវីដេអូពិសោធន៍ (Lab Protocol) លើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា។



*គ្រូឧទ្ទេសពីវិទ្យាស្ថានជាតិអប់រំដឹកនាំការធ្វើពិសោធន៍វិទ្យាសាស្ត្រនៅវិទ្យាល័យព្រះបាទសុរាម្រឹត*

ជាងនេះទៅទៀត វិទ្យាស្ថានជាតិអប់រំ បានជួយបង្វឹកនៅនឹងកន្លែងលើការរៀននិងបង្រៀនស្ទែម ការធ្វើពិសោធន៍វិទ្យាសាស្ត្រ កិច្ចការគម្រោង និងការវាយតម្លៃលើការរៀននិងបង្រៀនស្ទែមនៅសាលាមធ្យមសិក្សា នៅទូទាំងប្រទេស ជាពិសេស វិទ្យាល័យធនធានចំនួន៥០ និងវិទ្យាល័យបណ្តាញចំនួន៨៧ ក្នុងក្របខណ្ឌនៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2)។



### បណ្ណាល័យ

ឆ្លើយតបនឹងចក្ខុវិស័យរបស់វិទ្យាស្ថានជាតិអប់រំ បណ្ណាល័យវិទ្យាស្ថានជាតិអប់រំបានខិតខំកៀរគរប្រមូលឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយអប់រំ ច្បាប់អប់រំ វិធីសាស្ត្របង្រៀនថ្មីៗ និងឯកសារបណ្តុះបណ្តាលក្នុងក្របខណ្ឌរបស់វិទ្យាស្ថានជាតិអប់រំដូចជា៖ កម្មវិធីបរិញ្ញាបត្រ+២ អធិការអប់រំ បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ វិជ្ជាជីវៈនាយកសាលា ប្រឹក្សាគរុកោសល្យ វិធីសាស្ត្របង្រៀនភាសាបារាំង និងថ្នាក់បណ្ឌិត។ លើសពីនេះទៅទៀត បណ្ណាល័យវិទ្យាស្ថានជាតិអប់រំបានរៀបចំឯកសារទាំងនោះរួមមានទាំងផ្នែករឹង និងឌីជីថល ហើយក៏បានរៀបចំកម្មវិធីតម្រង់ទិសផ្សព្វផ្សាយដោយផ្ទាល់ និងតាមរយៈ Telegram &Facebook ដល់បុគ្គលិក គ្រូឧទ្ទេស សិស្ស និស្សិត គរុនិស្សិត និងសារធារណជនសម្រាប់សិក្សាស្រាវជ្រាវបន្ថែមក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។ ដូចនេះ បណ្ណាល័យមានតួនាទីសំខាន់ក្នុងការជំរុញអ្នកសិក្សាឱ្យងាកមកយកចិត្តទុកដាក់ លើការស្រាវជ្រាវដើម្បីលើកកម្ពស់ទម្លាប់នៃការអាន។

### សុខភាពសិក្សា

ដើម្បីគាំទ្រដល់ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ សេវាសុខភាពសិក្សា ដើរតួនាទីយ៉ាងសំខាន់។ ក្នុងន័យនេះ វិទ្យាស្ថានជាតិអប់រំបានអនុវត្តសកម្មភាពដូចខាងក្រោម ដើម្បីលើកកម្ពស់សុខភាពសិក្សា៖

១. រៀបចំបន្ទប់សុខភាពដោយមានដាក់សម្ភារ និងឱសថបានគ្រប់គ្រាន់សម្រាប់ការសង្គ្រោះបឋម
២. សៀវភៅពិនិត្យតាមដានសុខភាពសម្រាប់មន្ត្រី និងគរុនិស្សិតទាំងអស់
៣. សៀវភៅគោលការណ៍ប្រតិបត្តិបន្ទប់សុខភាព
៤. កត់ត្រាបញ្ជីឈ្មោះ និងបញ្ហាសុខភាពរបស់គរុនិស្សិត និងបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ
៥. គណៈកម្មការសុខភាពសិក្សា បានរៀបចំការធ្វើតេស្តសុខភាពសិស្ស គរុសិស្ស គរុនិស្សិត និងនិស្សិត និងបង្រៀនពីរបៀបពិនិត្យសុខភាព
៦. គណៈកម្មការសុខភាពសិក្សា បានរៀបចំកម្មវិធីពិគ្រោះយោបល់ជាមួយសិស្ស គរុសិស្ស គរុនិស្សិត និងនិស្សិតដែលមានបញ្ហាសុខភាពផ្លូវចិត្ត

សហការជាមួយនាយកដ្ឋានសុខភាពសិក្សា និងដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យគំហើញ និងការស្តាប់ និងចែករំលែកជូនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ និងគរុនិស្សិត។

### ការអនុវត្តវិធីសាស្ត្របង្រៀន

គរុនិស្សិតនឹងយកវិធីសាស្ត្របង្រៀនដែលបានទទួលពីការបណ្តុះបណ្តាល ទៅអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀន និងចែករំលែកដល់គ្រូបង្រៀននៅតាមសាលាគោលដៅ ដែលវិធីសាស្ត្របង្រៀនរួមមាន វិធីសាស្ត្របង្រៀនតាមបែបរិះរក (Inquiry Based Learning) វិធីសាស្ត្របង្រៀនតាមបែបដោះស្រាយបញ្ហា (Problem Based Learning) វិធីសាស្ត្របង្រៀនតាមបែបគម្រោង (Project Based Learning) វិធីវិទ្យាសាស្ត្រ (Scientific Method) វិធីសាស្ត្របង្រៀនតាមបែប 5Es ជាដើម។ គរុនិស្សិតនឹងប្រើប្រាស់វិធីសាស្ត្របង្រៀនទាំងនេះនៅក្នុងថ្នាក់ជាក់ស្តែង ដោយមានការសង្កេតពីគ្រូបង្រៀន ការឆ្លុះបញ្ចាំង ការរៀបចំកិច្ចតែងការបង្រៀន ការបង្រៀនជាក់ស្តែងរបស់គ្រូបង្រៀននៅតាមសាលាគោលដៅ ការសិក្សាពីមេរៀន (Lesson Study) និងការប្រជុំបច្ចេកទេស។ គរុនិស្សិតនឹងចែករំលែកវិធីសាស្ត្របង្រៀនទាំងនេះទៅដល់គ្រូបង្រៀន តាមរយៈការធ្វើសិក្ខាសាលាឬការប្រជុំប្រចាំខែ។

### សិក្ខាសាលា និងបាឋកថា

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យចូលរួមសិក្ខាសាលាយ៉ាងតិច ២ដង និងចូលរួមស្តាប់បាឋកថាតាមការចាត់តាំងរបស់វិទ្យាស្ថានជាតិអប់រំក្នុងរយៈពេលនៃការបណ្តុះបណ្តាល។

### ទស្សនកិច្ចសិក្សា

គរុនិស្សិតកម្រិតឧត្តមតម្រូវឱ្យធ្វើទស្សនកិច្ចសិក្សាតាមការចាំបាច់ ដើម្បីផ្សាភ្ជាប់ការបណ្តុះបណ្តាលទៅនឹងការអនុវត្ត

ជាក់ស្តែង និងបទពិសោធន៍នៅនឹងកន្លែង រួមទាំងជាការហ្វឹកហាត់ភាពជាអ្នកដឹកនាំការរៀននិងបង្រៀន និងភាពជាពលរដ្ឋសាកល។ ដំណើរទស្សនកិច្ចសិក្សាបានផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

បានផ្តល់ឱ្យគរុនិស្សិតនូវមេរៀនភាពជាអ្នកដឹកនាំការរៀន និងបង្រៀន ដែលលេចចេញពីការអនុវត្តផ្ទាល់នៃដំណើរទស្សនកិច្ចសិក្សាមួយនេះ។ គរុនិស្សិតបានសហការគ្នាក្នុងភាពជាក្រុម រៀបចំផែនការទស្សនកិច្ចសិក្សា (ផែនការសកម្មភាព វត្ថុបំណង និងផែនការថវិកា) ដោយបានរៀបចំក្រុមតូចៗសម្រាប់ទទួលខុសត្រូវលើមុខសញ្ញាការងារ។ មេរៀនភាពជាអ្នកដឹកនាំការរៀន និងបង្រៀនមួយនេះ និងចងក្រងចេញជាឯកសារសម្រាប់ជាជំនួយដល់គរុនិស្សិតប្រើប្រាស់នៅពេលបញ្ចប់ការបណ្តុះបណ្តាល ហើយយកធ្វើជាទស្សនាទានពេលចេញទៅបង្រៀននៅមូលដ្ឋានផ្ទាល់។

បានសង្កេតផ្ទាល់អំពីទម្រង់ លំនាំ និងដំណើការនៅទីកន្លែងជាក់ស្តែង។

បានចូលរួមការងារមនុស្សធម៌ ដោយចែករំលែកនូវធនធានមួយចំនួនដល់សិស្សានុសិស្សកំពុងជួបការលំបាកនៅក្នុងសហគមន៍ ផ្ទាល់ក្នុងភាពជាពលរដ្ឋសាកល (ឧទាហរណ៍៖ ទស្សនកិច្ចសិក្សាទៅកាន់ សាលាបឋមសិក្សាហ៊ុនសែនមិត្តភាព ក្រុងព្រះសីហនុ)។

បានផ្តល់នូវលំនាំនៃការសិក្សាបែបសតវត្សរ៍ទី២១ (ការសិក្សាគម្រោង) សម្រាប់គរុនិស្សិតយកទៅអនុវត្តផ្ទាល់ នៅពេលក្លាយខ្លួនទៅជាគ្រូបង្រៀនអាជីព។

## ការបញ្ចូលបច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិតសម្រាប់ការបង្រៀន និងរៀន

គ្រូឧទ្ទេសនិងគរុនិស្សិតប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងបញ្ញាសិប្បនិម្មិត ដើម្បីបម្រើឱ្យការបង្រៀននិងរៀន។ សម្ភារឌីជីថល និងគ្រឿងសង្ហារិម ត្រូវបានបំពាក់ និងរៀបចំក្នុងបន្ទប់ឌីជីថល។ ជាមួយគ្នានេះដែរ បន្ទប់ ICT ចំនួន៤ ដែលមានកុំព្យូទ័រលើតុចំនួន១២០ គ្រឿង ត្រូវបានរៀបចំឡើង ដើម្បីឱ្យគរុនិស្សិតប្រើប្រាស់ជំនួយដល់ការរៀន និងការស្រាវជ្រាវ។ កុំព្យូទ័រយួរដៃត្រូវបានចែកជូនគ្រូឧទ្ទេស និងបុគ្គលិកអប់រំទាំងអស់ រួមទាំងគ្រូបង្រៀននៅវិទ្យាល័យអនុវត្ត និងបឋមសិក្សាអនុវត្ត ដើម្បីឱ្យមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាគាំទ្រដល់ការបង្រៀនសិស្ស និងគរុនិស្សិត។

វិទ្យាស្ថានជាតិអប់រំបានសហការជាមួយអង្គការ KAPE, E-School Cambodia នាយកដ្ឋានបរិវត្តកម្មឌីជីថល សាលារៀនជំនាន់ថ្មី មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី និងដៃគូអភិវឌ្ឍន៍អន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពគ្រូឧទ្ទេស និងគរុនិស្សិតក្នុងការសរសេរកិច្ចតែងការបង្រៀនដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត។ អង្គភាពទាំងនេះនឹងបន្តគាំទ្រវិទ្យា-ស្ថានជាតិអប់រំ ដើម្បីកសាងសមត្ថភាពលើជំនាញផ្សេងៗទៀត ដែល AI អាចជួយគាំទ្រដល់ការបណ្តុះបណ្តាលឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំបានរៀបចំបន្ទប់ស្ទូឌីយោ ក្នុងគោលបំណងបង្កើតវីដេអូបង្រៀន ដែលប្រើប្រាស់វិធីសាស្ត្រថ្មីៗ ស្របតាមតម្រូវការសិស្ស និងតម្រូវការសង្គមនាពេលបច្ចុប្បន្ន។ បន្ទប់ស្ទូឌីយោនេះក៏នឹងដើរតួសំខាន់ក្នុងការថតនិងរក្សាទុកវីដេអូបង្រៀនរបស់គ្រូឧទ្ទេស គរុនិស្សិត និងបុគ្គលិកអប់រំ ក៏ដូចជាការរៀបចំមេរៀនឌីជីថលតាមរយៈការប្រើប្រាស់បញ្ញាសិប្បនិម្មិតផងដែរ។ បច្ចុប្បន្ននេះ បន្ទប់ស្ទូឌីយោសម្រាប់ថ្នាក់រៀនត្រឡប់ និងមេរៀនឌីជីថលនេះបានកំពុងប្រើប្រាស់ក្នុងការផលិតឯកសារបង្រៀន និងរៀនសម្រាប់គ្រូឧទ្ទេសនិងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ និងសម្រាប់វគ្គបណ្តុះបណ្តាលបន្តតាមរយៈសិក្ខាសាលា និងវគ្គសិក្សារយៈពេលខ្លីដល់គ្រូឧទ្ទេស និងគរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ និងគ្រូបង្រៀននានានៅតាមសាលារៀនចំណោះទូទៅនៅកម្ពុជា។




គ្រូឧទ្ទេសមុខវិជ្ជាសិល្បៈជាមួយគរុនិស្សិតក្នុងកម្មវិធីពិព័រណ៍អប់រំ

ជំពូក
៤

# ការបណ្តុះបណ្តាល ថ្នាក់ក្រោយបរិញ្ញាបត្រ

សាលាក្រោយបរិញ្ញាបត្រ (Graduate School) ជាផ្នែកមួយក្នុងចំណោមផ្នែកធំៗបួន នៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់វិទ្យាស្ថានជាតិអប់រំ ដែលត្រូវបានបង្កើតឡើងតាមអនុក្រឹត្យលេខ១៨៩ អនក្រ.បក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។ តាមប្រកាសលេខ១៧៨៥ អយក.ប្រក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ សាលាក្រោយបរិញ្ញាបត្រ ចែកចេញជា៣ដេប៉ាតឺម៉ង់៖ ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការអប់រំ និងដេប៉ាតឺម៉ង់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ សាលាក្រោយបរិញ្ញាបត្រមានតួនាទី និងភារកិច្ចក្នុងការបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ទាំងការបណ្តុះបណ្តាលដំបូង និងបណ្តុះបណ្តាលបន្ត។ សាលាក្រោយបរិញ្ញាបត្រមានកំណើតចេញពីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ។ ដោយមើលពីទំហំការងារជាច្រើន ដែលដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការទទួលបន្ទុក ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការដំឡើងដេប៉ាតឺម៉ង់នេះ ទៅជាសាលាក្រោយបរិញ្ញាបត្រ។

## ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រ

ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រ មានភារកិច្ចចម្បងក្នុងការអនុវត្តការបណ្តុះបណ្តាលដំបូង ដើម្បីដំឡើងកម្រិតគុណវុឌ្ឍិដល់មន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ ទាំងលើផ្នែកគ្រប់គ្រង និងការបង្រៀននិងរៀន។ វគ្គបណ្តុះបណ្តាលដំបូងដែលកំពុងបណ្តុះបណ្តាលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រ រួមមាន៖ (១)ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ (២)ថ្នាក់បណ្ឌិតអប់រំឯកទេសអភិវឌ្ឍកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន (៣)ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ និង (៤)ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិធីសាស្ត្របង្រៀនភាសាបារាំង តាមរូបភាពអាហារូបករណ៍ និងការបង់ថ្លៃសេវាសិក្សា។ ជាទិសដៅនាពេលខាងមុខ ដេប៉ាតឺម៉ង់ក្រោយបរិញ្ញាបត្រនឹងពង្រីកការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញផ្សេងៗទៀតទៅតាមតម្រូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ១. ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតអប់រំឯកទេសគ្រប់គ្រងអប់រំ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងអប់រំ យុវជន និងកីឡា

ក្របខ័ណ្ឌកម្មវិធីសិក្សា

ថ្នាក់បណ្ឌិតអប់រំ
ឯកទេសគ្រប់គ្រងអប់រំ
Doctor of Philosophy in Educational Management

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៤




ពិធីការពារនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាន់ទី១



ពិធីការពារនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាន់ទី១



ពិធីការពារនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាន់ទី១

ក្របខណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រងអប់រំ ត្រូវបានបង្កើតឡើងក្នុងគោលបំណង បណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជា៖ (១) អ្នកស្រាវជ្រាវការគ្រប់គ្រងអប់រំ អ្នករៀបចំគោលនយោបាយអប់រំ និងអ្នករៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងវិស័យអប់រំ ប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ និង (២) អ្នកជំនាញគ្រប់គ្រងអប់រំ មានសមត្ថភាពអនុវត្តទ្រឹស្តីអប់រំក្នុងបរិបទជាតិ តំបន់ និងសាកល។ អ្នកសិក្សាដែលបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ គឺជាបុគ្គលដែលមានគុណតម្លៃសម្រាប់សង្គមជាតិ និងពិភពលោក។ អ្នកសិក្សាត្រូវមានសម្បទាស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ រួមមាន ចំណេះដឹង ជំនាញការគិតវិភាគ ទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ ជំនាញលេខនព្វន្ត និងព័ត៌មានវិទ្យានិងទំនាក់ទំនង។

បេក្ខជនដែលមានបំណងចូលរៀនថ្នាក់បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ នៅសាលាក្រោយបរិញ្ញាបត្រនៃវិទ្យាស្ថានជាតិអប់រំ ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសចំនួនពីរដំណាក់កាល គឺការប្រឡងសំណេរ និងការអនុវត្ត។ បេក្ខជនដែលមានសិទ្ធិដាក់ពាក្យប្រឡងបាន លុះត្រាតែបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយសរសេរសារណា និងមានគម្រោងសំណើស្រាវជ្រាវបឋម។

មកត្រឹមឆ្នាំសិក្សា ២០២៤-២០២៥នេះ មាននិស្សិតថ្នាក់បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ ចំនួន៥ជំនាន់កំពុងសិក្សា និងស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួន។ តារាងខាងក្រោមបង្ហាញពីស្ថិតិនិស្សិតតាមជំនាន់នីមួយៗ។

| ជំនាន់ | ចំនួននិស្សិតសរុប | ស្រី | ឆ្នាំសិក្សាចាប់ផ្តើម |
|---|---|---|---|
| ទី១ | ១៤ | ០៣ | ២០២០-២០២១ |
| ទី២ | ១៣ | ០១ | ២០២១-២០២២ |
| ទី៣ | ១១ | ០០ | ២០២២-២០២៣ |
| ទី៤ | ១៣ | ០៦ | ២០២៣-២០២៤ |
| ទី៥ | ០៤ | ០០ | ២០២៤-២០២៥ |
| សរុប | ៥៥ | ១០ | |

### ២. ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន

ក្របខណ្ឌកម្មវិធីសិក្សាថ្នាក់បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ត្រូវបានបង្កើតឡើង ក្នុងគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជា៖ អ្នកស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីសិក្សា រួមមានការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃកម្មវិធីសិក្សា ប្រកបដោយសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ។ អ្នកស្រាវជ្រាវនិងអភិវឌ្ឍផ្នែកវិធីសាស្ត្របង្រៀន រួមមានការអភិវឌ្ឍ ការអនុវត្តការវាយតម្លៃការបង្រៀន ប្រកបដោយសមត្ថភាពនិងក្រមសីលធម៌វិជ្ជាជីវៈ។ អ្នកសិក្សាដែលបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតអប់រំ ជំនាញគ្រប់គ្រង អប់រំ គឺជាបុគ្គលដែលមានគុណតម្លៃសម្រាប់សង្គមជាតិ និងពិភពលោក។ អ្នកសិក្សា ត្រូវមានសម្បទា ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិរួមមាន ចំណេះដឹង ជំនាញការគិតវិភាគ ទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវជំនាញ លេខនព្វន្ត និងព័ត៌មានវិទ្យានិងទំនាក់ទំនង។

បេក្ខជនដែលមានបំណងចូលរៀនថ្នាក់បណ្ឌិតអប់រំ ឯកទេស




អភិវឌ្ឍកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន នៅសាលាក្រោយបរិញ្ញាបត្រនៃវិទ្យាស្ថានជាតិអប់រំ ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសចំនួនពីរដំណាក់កាល គឺការប្រឡងវិញ្ញាសាសំណេរ និងការអនុវត្ត។ បេក្ខជនដែលមានសិទ្ធិដាក់ពាក្យប្រឡងបាន លុះត្រាតែបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដោយការសរសេរសារណា មានគម្រោងសំណើស្រាវជ្រាវបឋម និងមានលក្ខណសម្បត្តិបន្ថែមផ្សេងៗទៀត ដែលកំណត់ដោយគណៈកម្មការជ្រើសរើសនិស្សិតចូលសិក្សា។

មកត្រឹមឆ្នាំសិក្សា ២០២៤-២០២៥នេះ មាននិស្សិតថ្នាក់បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ចំនួន៣ជំនាន់ កំពុងសិក្សា និងស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួន។ តារាងខាងក្រោមបង្ហាញពីស្ថិតិនិស្សិតតាមជំនាន់នីមួយៗ។

| ជំនាន់ | ចំនួននិស្សិតសរុប | ស្រី | ឆ្នាំសិក្សាចាប់ផ្តើម |
|---|---|---|---|
| ទី១ | ០៥ | ០១ | ២០២០-២០២៣ |
| ទី២ | ០៧ | ០១ | ២០២១-២០២៤ |
| ទី៣ | ១០ | ០២ | ២០២២-២០២៥ |
| សរុប | ២២ | ៤ | |

## ៣. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រងអប់រំ

កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រងអប់រំ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈមន្ត្រីអប់រំ ទាំងផ្នែកចំណេះដឹង និងជំនាញថ្មីៗ ក្នុងការបំពេញ តួនាទីជាមន្ត្រីរដ្ឋបាលអប់រំ អ្នកធ្វើផែនការអប់រំ អ្នកដឹកនាំ និងគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងប្រសិទ្ធភាព សម្រាប់ធ្វើការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចសង្គម។ កម្មវិធីសិក្សានេះ មានរយៈពេល២ឆ្នាំ និងត្រូវចែកចេញជា២ផ្នែកធំៗគឺ ការសិក្សាស្រាវជ្រាវក្នុងថ្នាក់ រយៈពេល១៨ខែ និងការសរសេរនិក្ខេបបទ រយៈពេល៦ខែ។

បេក្ខជន ដែលមានបំណងចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រងអប់រំ នៅសាលាក្រោយបរិញ្ញាបត្រនៃវិទ្យាស្ថានជាតិអប់រំ ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសទាំង




ថ្នាក់អាហារូបករណ៍ និងថ្នាក់បង់ថ្លៃសេវាសិក្សា។ សម្រាប់ថ្នាក់អាហារូបករណ៍ បេក្ខជនដែលមានសិទ្ធិដាក់ពាក្យប្រឡងបាន លុះត្រាតែជាបុគ្គលិកក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា មានបទពិសោធន៍ការងាររយៈពេល៥ឆ្នាំ និងមានសញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រសមមូល។ សម្រាប់ថ្នាក់បង់ថ្លៃសេវាសិក្សា បេក្ខជនត្រូវប្រឡងជ្រើសរើសក្នុងចំណោមបេក្ខជនទូទៅ និងមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល។

គិតត្រឹមឆ្នាំ២០២៥នេះ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញា-បត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រងអប់រំ ដំណើរការបាន ១៣ជំនាន់ហើយ។ ខាងក្រោមគឺជាតារាងនិស្សិតតាមជំនាន់៖

| ជំនាន់ | ឆ្នាំសិក្សា | ចំនួននិស្សិតចូលរៀនជាក់ស្តែង | ចំនួននិស្សិតចូលបានបញ្ចប់ការសិក្សា |
|---|---|---|---|
| ១ | ២០១២-២០១៤ | ២០ (០៤) | ១៧ (ស្រី ០៤) |
| ២ | ២០១៣-២០១៥ | ២៣ (០៦) | ១៨ (ស្រី ០៤) |
| ៣ | ២០១៤-២០១៦ | ២៣ (០៧) | ១៥ (ស្រី ០៦) |
| ៤ | ២០១៥-២០១៧ | ២៥ (០៦) | ២០ (ស្រី ០៦) |
| ៥ | ២០១៦-២០១៨ | ២៤ (០៣) | ២៣ (ស្រី ០៣) |
| ៦ | ២០១៧-២០១៩ | ៤១ (០៥) | ៤០ (ស្រី ០៥) |
| ៧ | ២០១៨-២០២០ | ៥៧ (១៦) | ៣៩ (ស្រី ១៣) |
| ៨ | ២០២០-២០២២ | ៣១ (០៩) | ២៧ (ស្រី ០៤) |
| ៩ | ២០២១-២០២៣ | ៥៨ (១៩) | ៥៤ (ស្រី ១៩) |
| ១០ | ២០២២-២០២៤ | ៤៨ (១១) | ៣៤ (ស្រី ០៨) |
| ១១ | ២០២៣-២០២៥ | ៤៥ (២១) | ៤៥ (ស្រី ១៦) |
| ១២ | ២០២៤-២០២៥ | ៣៨ (១៩) | កំពុងសិក្សា |
| ១៣ | ២០២៤-២០២៦ | ៤៤ ( ១៨) | កំពុងសិក្សា |
| សរុប | | ៣៣២ (៨៦) | |

## ៤. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់វិធីសាស្ត្របង្រៀនភាសាបារាំង


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

កម្មវិធីសិក្សាលម្អិតសម្រាប់
ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម
(បរិញ្ញាបត្រ+២)

មុខវិជ្ជាស្នូលនៃឯកទេស
ឯកទេស

វិទ្យាស្ថានជាតិអប់រំ

កញ្ញា ២០២៣

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិធីសាស្ត្របង្រៀនភាសាបារាំង ផ្តល់ជូនអ្នកសិក្សា នូវជំនាញមូលដ្ឋានចាំបាច់នានា តាមរយៈសាស្ត្រាចារ្យជំនាញ ប្រកបដោយចំណេះដឹង និងសមត្ថភាពជំនាញ ដើម្បីឱ្យនិស្សិតមានឱកាសក្នុងការបង្កើនការសិក្សាឱ្យបានជាអតិបរមា។ កម្មវិធីបណ្តុះបណ្តាលនេះ មានគោលបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យក្លាយជាគ្រូបង្រៀនភាសាបារាំង លើផ្នែកគរុកោសល្យ និងពង្រឹងសមត្ថភាពភាសាបារាំង និងវប្បធម៌បារាំង។ ម្យ៉ាងទៀត នៅក្នុងផ្នែកគរុកោសល្យ និងការស្រាវជ្រាវកម្មវិធីបណ្តុះបណ្តាលមានគោលបំណងអភិវឌ្ឍសមត្ថភាពរបស់អ្នកសិក្សាក្នុងការស្រាវជ្រាវឯកសារអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ ដែលបានចុះផ្សាយតាមប្រភពព័ត៌មាននានា សម្រាប់បម្រើឱ្យសកម្មភាពបង្រៀន (ការស្រាវជ្រាវសកម្មភាពវិជ្ជាជីវៈ) វិភាគ សំយោគ និងការត្រិះរិះ កម្រិតខ្ពស់ ដែលជាការពង្រឹងគុណភាពនៃការស្រាវជ្រាវអនុវត្ត។

បេក្ខជន ដែលមានសិទ្ធិដាក់ពាក្យប្រឡង ត្រូវមាន ៖ បរិញ្ញាបត្រភាសាបារាំង ឬបរិញ្ញាបត្រសមមូល មានបទពិសោធន៍បង្រៀនភាសាបារាំងមួយឆ្នាំ ហើយបេក្ខជនដែលជាបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា អាចចុះឈ្មោះប្រឡងជ្រើសរើសថ្នាក់អាហារូបករណ៍ ទៅតាមចំនួនដែលបានកំណត់។

មកត្រឹមឆ្នាំ២០២៥នេះ និស្សិតដែលបានចុះឈ្មោះចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិធីសាស្ត្របង្រៀនភាសាបារាំង បានចំនួន៦ជំនាន់ ដូចក្នុងតារាងក្រោម៖

| ជំនាន់ | ចំនួននិស្សិតសរុប | ស្រី | ឆ្នាំសិក្សា |
|---|---|---|---|
| ទី១ | ២២ | ៩ | ២០១៩-២០២១ |
| ទី២ | ១៤ | ៧ | ២០២០-២០២២ |
| ទី៣ | ១៤ | ៩ | ២០២១-២០២៣ |
| ទី៤ | ១២ | ៧ | ២០២២-២០២៤ |
| ទី៥ | ២១ | ១៤ | ២០២៣-២០២៥ |
| ទី៦ | ១២ | ៧ | ២០២៤-២០២៦ |
| សរុប | ៩៥ | ៥៣ | |

## ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការអប់រំ

ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការអប់រំ មានភារកិច្ចចម្បងក្នុងការអនុវត្តការបណ្តុះបណ្តាលដំបូង ដើម្បីដំឡើងកម្រិតគុណវុឌ្ឍិដល់មន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ ទាំងលើផ្នែកគ្រប់គ្រង និងអធិការកិច្ចសាលារៀន។ វគ្គបណ្តុះបណ្តាលដំបូងដែលកំពុងបណ្តុះបណ្តាលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការអប់រំ រួមមាន៖ (១)ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអធិការអប់រំ (២)បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលារៀន និង (៣) ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។

### ១. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអធិការកិច្ចអប់រំ

កម្មវិធីបណ្តុះបណ្តាលថ្នាក់អធិការកិច្ចអប់រំ មានបំណងបណ្តុះបណ្តាលអ្នកសិក្សាឱ្យមានចំណេះដឹង និងជំនាញអធិការកិច្ច ដើម្បីទៅបម្រើការងារនៅតាមតំបន់អធិការកិច្ចចំនួន៨ ដែលបានជ្រើសរើស នៅក្នុងទូទាំងប្រទេសកម្ពុជា ជាពិសេសដើម្បីឱ្យមន្ត្រីអធិការកិច្ចមានគុណតម្លៃទាំងនៅក្នុងតំបន់ និងអន្តរជាតិ។ កម្មវិធីបណ្តុះបណ្តាលថ្នាក់អធិការកិច្ចអប់រំនេះ ក៏រួមចំណែកអភិវឌ្ឍសង្គមពុទ្ធិប្រកបដោយនិរន្តរភាព ដោយធ្វើការបណ្តុះបណ្តាល ជូនដល់មន្ត្រីគ្រប់គ្រងអប់រំ និងមន្ត្រីអធិការកិច្ចឱ្យចេះទាំងផ្នែកចំណេះដឹង និងជំនាញអធិការកិច្ចជាប្រព័ន្ធ ការវិភាគ និងការសរសេររបាយការណ៍អធិការកិច្ច និងឥរិយាបថក្នុងការងារអធិការកិច្ច ឱ្យស្របទៅនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាដើម្បីចូលរួមសម្រេចឱ្យបានចំពោះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានបំណងចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអធិការកិច្ចអប់រំ ត្រូវឆ្លងកាត់ការប្រឡងចូលរៀន។ បេក្ខជនដែលអាចដាក់ពាក្យប្រឡងក្នុងការជ្រើសរើសឱ្យចូលរៀន ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ និងត្រូវគោរពតាមលក្ខខណ្ឌផ្សេងៗទៀតតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា។




និស្សិតអធិការអប់រំចំនួន៧ជំនាន់ បានបញ្ចប់ការសិក្សាដោយជោគជ័យ ហើយកំពុងបម្រើការនៅតាមស្ថាប័ននានានៃក្រសួងអប់រំ យុវជន និងកីឡា ដូចក្នុងតារាងខាងក្រោម៖

| ជំនាន់ | ចំនួនសរុប | ស្រី | ឆ្នាំសិក្សា |
|---|---|---|---|
| ទី១ | ៣១ | ៣ | ២០១៥-១៦ |
| ទី២ | ៧៣ | ៩ | ២០១៦-១៧ |
| ទី៣ | ៤០ | ៤ | ២០១៧-១៨ |
| ទី៤ | ៦០ | ៩ | ២០១៨-១៩ |
| ទី៥ | ៥២ | ១១ | ២០១៩-២០ |
| ទី៦ | ១៧ | ២ | ២០២១-២២ |
| ទី៧ | ១៩ | ៦ | ២០២៣-២៤ |
| សរុប | ២៩២ | ៤៤ | |

## ២. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលារៀន

វគ្គបណ្ដុះបណ្ដាលនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ដល់គណៈគ្រប់គ្រង ឬនាយកសាលាមធ្យមសិក្សាទុតិយភូមិ ស្របតាមស្តង់ដាតំបន់ និងអន្តរជាតិ និងដើម្បីតម្រង់ទិសដល់ការដឹកនាំ និងការគ្រប់គ្រងឆ្ពោះទៅបំពេញបាននូវស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដែលធានាបាននូវលទ្ធផលសិក្សាល្អសម្រាប់សិស្សានុសិស្ស។ គណៈគ្រប់គ្រង ឬនាយកសាលារៀនមានសមត្ថភាព មនសិការវិជ្ជាជីវៈ និងភាពជាអ្នកដឹកនាំ ដែលផ្ដល់ការគាំទ្រដល់គ្រូបង្រៀនឱ្យទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងអ្នកសិក្សា ឱ្យទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមពុទ្ធិប្រកបដោយចីរភាព ជាពិសេសផ្ដល់នូវចំណេះដឹង និងជំនាញច្បាស់លាស់លើការគ្រប់គ្រង និងការដឹកនាំសាលារៀនប្រកបដោយប្រសិទ្ធភាព។




វគ្គបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលារៀន បើកបណ្ដុះបណ្ដាលក្នុងរូបភាពអាហារូបករណ៍ និងបង់ថ្លៃសិក្សា។ បេក្ខជនត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសដើម្បីចូលរៀន។ បេក្ខជនដែលអាចដាក់ពាក្យប្រឡងចូលរៀនសម្រាប់ថ្នាក់អាហារូបករណ៍ ត្រូវតែជាបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា មាន

បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ មានបទពិសោធន៍ការងារចាប់ពី៣ឆ្នាំឡើងទៅ និងមានវិញ្ញាបនបត្ររដ្ឋបាលដែលចេញដោយប្រធានអង្គភាព។ ចំណែកបេក្ខជនដែលអាចដាក់ពាក្យប្រឡងចូលរៀនសម្រាប់បង់ថ្លៃសិក្សាត្រូវមានបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

និស្សិតចំនួន៧ជំនាន់ បានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ និងកំពុងបម្រើការនៅតាមគ្រឹះស្ថានអប់រំនានា ទាំងគ្រឹះស្ថានសាធារណៈ និងឯកជន ដូចក្នុងតារាងខាងក្រោម៖

| ជំនាន់ | ចំនួនសរុប | ស្រី | ឆ្នាំសិក្សា |
|---|---|---|---|
| ទី១ | ១៨ | ១ | ២០១៧-១៨ |
| ទី២ | ១២ | ០ | ២០១៨-១៩ |
| ទី៣ | ២៩ | ៧ | ២០១៩-២០ |
| ទី៤ | ១៩ | ៣ | ២០២០-២១ |
| ទី៥ | ២២ | ៧ | ២០២១-២២ |
| ទី៦ | ១៥ | ៥ | ២០២២-២៣ |
| ទី៧ | ១៦ | ៨ | ២០២៣-២៤ |
| សរុប | ១៣១ | ៣១ | |

### ៣. ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ

កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៩ ដើម្បីដោះស្រាយតម្រូវការគ្រូប្រឹក្សាគរុកោសល្យ ដែលមានសមត្ថភាព ជាពិសេសនៅក្នុងសាលារៀនជំនាន់ថ្មី។ កម្មវិធីនេះមានគោលបំណងបណ្តុះបណ្តាលគ្រូបង្រៀន ដែលមានបទពិសោធន៍ក្នុងការផ្តល់សេវាប្រឹក្សាគរុកោសល្យតាមរយៈការសង្កេតថ្នាក់រៀន ការណែនាំវិជ្ជាជីវៈ និងការគាំទ្រផ្នែកគរុកោសល្យ។ល។ កម្មវិធីបណ្តុះបណ្តាលនេះ មានរយៈពេល១ឆ្នាំ ៤ខែ ស្មើនឹង៥៤ក្រេឌីត មានមុខវិជ្ជាស្នូលចំនួន ៤ (ក្រមសីលធម៌វិជ្ជាជីវៈនិងការប្រឹក្សាគរុកោសល្យ ការស្រាវជ្រាវអប់រំបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្រាប់ការអប់រំ និងវិធីសាស្ត្របង្រៀន) កម្មសិក្សាប្រតិបត្តិគរុកោសល្យ និងសរសេរសារណា។

បេក្ខជនដែលមានបំណងចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ នៅវិទ្យាស្ថានជាតិអប់រំត្រូវឆ្លងកាត់ការប្រឡងចូល។ បេក្ខជនដែលមានសិទ្ធិដាក់ពាក្យប្រឡង ត្រូវជាគ្រូបង្រៀនក្របខណ្ឌរដ្ឋ ដែលមានបទពិសោធន៍បង្រៀនយ៉ាងតិច៥ឆ្នាំ មានសញ្ញាបត្របរិញ្ញាបត្រអប់រំ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ឬមានសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម(BA + 1 ឬ BA +2) មានចំណេះដឹងភាសាអង់គ្លេស និង ICT កម្រិតមធ្យម។ ការប្រឡងចូលរួមមានដូចជា៖ តេស្តគរុកោសល្យ ភាសាអង់គ្លេស ការបង្រៀនបង្ហាញ និងសម្ភាសន៍ផ្ទាល់មាត់។

មកត្រឹមឆ្នាំ២០២៥ វិទ្យាស្ថានជាតិអប់រំបានបណ្តុះបណ្តាលគ្រូប្រឹក្សាគរុកោសល្យបានចំនួន៥ជំនាន់មកហើយ ដូចក្នុងតារាងខាងក្រោម៖

| ជំនាន់ | ចំនួនគរុនិស្សិតសរុប | ស្រី | ឆ្នាំសិក្សា |
|---|---|---|---|
| ទី១ | ២៥ | ១១ | ២០១៩-២០២០ |
| ទី២ | ៣២ | ១៣ | ២០២០-២០២១ |
| ទី៣ | ២១ | ០៧ | ២០២១-២០២២ |
| ទី៤ | ២៥ | ១១ | ២០២២-២០២៣ |
| ទី៥ | ៣១ | ១៧ | ២០២៣-២០២៤ |
| សរុប | ១៣៣ | ៥៩ | |

## ដេប៉ាតឺម៉ង់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ដេប៉ាតឺម៉ង់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ទទួលអនុវត្តការបណ្ដុះបណ្ដាលបន្តរបស់វិទ្យាស្ថាន ដល់មន្ត្រីគ្រប់គ្រងអប់រំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងតាមរូបភាពអាហារូបករណ៍រដ្ឋ និងរូបភាពបង់ថ្លៃសេវាសិក្សា។ ដេប៉ាតឺម៉ង់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ បានធ្វើការបណ្ដុះបណ្ដាលបន្តដល់មន្ត្រីគ្រប់គ្រងអប់រំ នាយកសាលារៀន និងគ្រូបង្រៀននៅទូទាំងប្រទេស។ វិទ្យាស្ថានជាតិអប់រំកំពុងផ្ដល់វគ្គសិក្សាសម្រាប់វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំថ្នាក់បង់ថ្លៃសិក្សា ចំនួន៥កម្មវិធីដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងមានការកត់ត្រាចំនួនក្រេឌីតសម្រាប់គ្រូក្របខណ្ឌរដ្ឋ ដើម្បីប្រើប្រាស់សម្រាប់វាយតម្លៃឡើងគន្លងអាជីពគ្រូបង្រៀន។

### ១. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញគរុកោសល្យ និងវិធីសាស្ត្របង្រៀន

វគ្គបណ្ដុះបណ្ដាលនេះ ផ្ដោតលើចំណេះដឹងបំណិនគរុកោសល្យ និងវិធីសាស្ត្របង្រៀនសម្រាប់សាលារៀនចំណេះទូទៅ និងគ្រឹះស្ថានឧត្ដមសិក្សាឯកជន ស្របតាមទ្រឹស្ដីអប់រំបែបស្ថាបនានិយម និងនិន្នាការអប់រំសតវត្សរ៍ទី២១ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាកំណែទម្រង់គ្រូបង្រៀនសាលាចំណេះទូទៅ នៅទូទាំងប្រទេសផងដែរ។ កម្មវិធីបណ្ដុះបណ្ដាលនេះមានរយៈពេល១៥សប្ដាហ៍ និងបែងចែកជា៩០ម៉ោង (៦ក្រេឌីត)។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

វិញ្ញាបនបត្រ
ទទួលស្គាល់គុណភាពការផ្ដល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

គណៈកម្មការសម្រាប់ពិនិត្យ វាយតម្លៃ និងផ្ដល់ការទទួលស្គាល់គុណភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
ផ្ដល់
ការទទួលស្គាល់គុណភាពបណ្ដោះអាសន្ន
ដល់
កម្មវិធីបណ្ដុះបណ្ដាលស្ដីពី
ចិត្ត-គរុកោសល្យ វិធីសាស្ត្របង្រៀន និង សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន
ចំនួន ៦ ក្រេឌីត

របស់វិទ្យាស្ថានជាតិអប់រំ ដែលបានបំពេញតាមលក្ខខណ្ឌ នៃការផ្ដល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានរយៈពេល ០៣ ឆ្នាំ ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ។

ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

លក្ខខណ្ឌនៃការបណ្ដុះបណ្ដាលគរុកោសល្យ និងវិធីសាស្ត្របង្រៀននេះផ្ដោតលើកញ្ចប់មុខវិជ្ជាធំៗចំនួន៣គឺ៖

- មុខវិជ្ជាចិត្ត-គរុកោសល្យ (៣០ម៉ោង ស្មើនឹង២ក្រេឌីត)
- មុខវិជ្ជាវិធីសាស្ត្របង្រៀន (៣០ម៉ោង ស្មើនឹង២ក្រេឌីត)
- មុខវិជ្ជាសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន (៣០ម៉ោង ស្មើនឹង២ក្រេឌីត)

## ២. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញនាយកសាលារៀន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៧៤៦ អយក.ប្រក

វិញ្ញាបនបត្រ
ទទួលស្គាល់គុណភាពការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
ផ្តល់
ការទទួលស្គាល់គុណភាពពេញសិទ្ធិ
ដល់
កញ្ចប់សមត្ថភាពលើការបណ្តុះបណ្តាលស្តីពី
ការគ្រប់គ្រងរដ្ឋបាល ការបង្រៀននិងការរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក
ចំនួន ៦ ក្រេឌីត

របស់វិទ្យាស្ថានជាតិអប់រំ ដែលបានបំពេញតាមលក្ខខណ្ឌ នៃការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានរយៈពេល ០៥ ឆ្នាំ ចាប់ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៧ ។

ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០២២
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

វគ្គបណ្តុះបណ្តាលនេះ ផ្តោតលើខ្លឹមសារសំខាន់ៗ រួមមាន គំនិតជាយុទ្ធសាស្ត្រនិងនវានុវត្តន៍ ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងការរៀន និងបង្រៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និង ការគ្រប់គ្រងបុគ្គលិក ដោយខ្លឹមសារនីមួយៗ រួមមានការសិក្សាទ្រឹស្តី ការអនុវត្ត និងការសិក្សាស្រាវជ្រាវ។ កម្មវិធីបណ្តុះបណ្តាលនេះ មានរយៈពេល១៥សប្តាហ៍ និងបែកចែកជា៩០ម៉ោង (៦ក្រេឌីត)។

លក្ខខណ្ឌនៃការបណ្តុះបណ្តាលមុខជំនាញនាយកសាលារៀននេះផ្តោតលើកញ្ចប់មុខវិជ្ជាធំៗចំនួន៥គឺ៖

- ម៉ូឌុល១៖ គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍ (១៥ម៉ោង ស្មើនឹង១ក្រេឌីត)
- ម៉ូឌុល២៖ ការគ្រប់គ្រងរដ្ឋបាល (១៥ម៉ោង ស្មើនឹង១ក្រេឌីត)
- ម៉ូឌុល៣៖ ការគ្រប់គ្រងការរៀន និងបង្រៀន (៣០ម៉ោង ស្មើនឹង២ក្រេឌីត)
- ម៉ូឌុល៤៖ ការគ្រប់គ្រងហិរញ្ញវត្ថុ (១៥ម៉ោង ស្មើនឹង១ក្រេឌីត)
- ម៉ូឌុល៥៖ ការគ្រប់គ្រងបុគ្គលិក (១៥ម៉ោង ស្មើនឹង១ក្រេឌីត)

## ៣. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញអធិការកិច្ច



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១០៦៤ អយក.ប្រក

វិញ្ញាបនបត្រ
ទទួលស្គាល់គុណភាពការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
ផ្តល់
ការទទួលស្គាល់គុណភាពពេញសិទ្ធិ
ដល់
ការបណ្តុះបណ្តាលស្តីពី
ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ
ចំនួន ២ ក្រេឌីត

របស់វិទ្យាស្ថានជាតិអប់រំ ដែលបានបំពេញតាមលក្ខខណ្ឌ នៃការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានរយៈពេល ០៥ ឆ្នាំ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៨ ។

ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

info@moeys.gov.kh / administration@moeys.gov.kh www.moeys.gov.kh

វគ្គបំប៉នស្តីពីប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ ផ្តោតលើអធិការកិច្ចជាប្រព័ន្ធចាប់ពីថ្នាក់ជាតិ ខេត្ត ស្រុក និងកម្រិតសាលារៀន។ អធិការកិច្ចអប់រំប្រព័ន្ធថ្មី សារៈតារអធិការកិច្ចនៅប្រទេសកម្ពុជា និងការបង្ហាញយ៉ាងពិស្តាររវាងអធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅ។ អធិការកិច្ចនឹងត្រូវយកទៅបង្ហាញយ៉ាងលម្អិតក្នុងវគ្គសិក្សានេះ ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ព្រោះជាធាតុយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពបង្រៀន និងរៀន។ កម្មវិធីបណ្តុះបណ្តាលនេះមានរយៈពេល៤សប្តាហ៍ និងបែងចែកជា៣០ម៉ោង (២ក្រេឌីត)។

លក្ខខណ្ឌនៃការបណ្តុះបណ្តាលមុខជំនាញអធិការកិច្ចនេះផ្តោតលើកញ្ចប់មុខវិជ្ជាធំៗចំនួន៣គឺ៖

- ម៉ូឌុល១៖ បញ្ញត្តិនៃការធានាគុណភាពអប់រំ (៧,៥ម៉ោង ស្មើនឹង០,៥ក្រេឌីត)
- ម៉ូឌុល២៖ ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត (៧,៥ម៉ោង ស្មើនឹង០,៥ក្រេឌីត)
- ម៉ូឌុល៣៖ ការវិភាគ និងវាយតម្លៃរបាយការណ៍អធិការកិច្ច (១៥ម៉ោង ស្មើនឹង១ក្រេឌីត)

## ៤. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញការគ្រប់គ្រងបណ្ណាល័យ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២០៤២ អយក.ឋស

វិញ្ញាបនបត្រ
ទទួលស្គាល់គុណភាពការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
ផ្តល់
ការទទួលស្គាល់គុណភាពជាបណ្តោះអាសន្ន
ដល់
ការបណ្តុះបណ្តាលស្តីពី
ការគ្រប់គ្រងបណ្ណាល័យមធ្យមសិក្សា
ចំនួន ២ ក្រេឌីត
របស់វិទ្យាស្ថានជាតិអប់រំ ដែលបានបំពេញតាមលក្ខខណ្ឌ នៃការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានរយៈពេល ០៣ ឆ្នាំ ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ។

ថ្ងៃ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដើម្បីបំប៉នចំណេះដឹង និងចំណេះធ្វើបន្ថែមដល់បណ្ណារក្សនៅតាមគ្រឹះស្ថានសាធារណៈ និងឯកជនដើម្បីឱ្យពួកគាត់មានសមត្ថភាពក្នុងការរៀបចំបណ្ណាល័យអនុលោមតាមស្តង់ដាបណ្ណាល័យសតវត្សរ៍ទី២១។ វគ្គនេះក៏បានបញ្ចូលផងដែរ នូវបច្ចេកទេសចុះកាតាឡុកដោយការចាត់សៀវភៅទៅតាមចំណាត់ថ្នាក់ដែលអាចឱ្យមានការរៀបចំសៀវភៅក្នុងបណ្ណាល័យប្រកបដោយភាពច្បាស់លាស់ មានបទដ្ឋានត្រឹមត្រូវងាយស្រួលក្នុងការស្វែងរករបស់សិស្ស និងអ្នកអាន។ ជាងនេះទៅទៀតវគ្គនេះក៏បានណែនាំឱ្យបណ្ណារក្សយល់ដឹងពីតួនាទីសំខាន់ៗរបស់ខ្លួន ក្នុងការរួមចំណែកដល់ការបង្រៀន និងរៀនដែលនាំឱ្យមានការកើនឡើងនូវលទ្ធផលសិក្សារបស់សិស្សផងដែរ។ កម្មវិធីបណ្តុះបណ្តាលនេះ មានរយៈពេល៤សប្តាហ៍ និងបែងចែកជា៣០ម៉ោង (២ក្រេឌីត)។

កម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រងបណ្ណាល័យមធ្យមសិក្សាផ្តោតលើមេរៀនសំខាន់ៗគឺ៖ បណ្ណារក្សសាលារៀន ការគ្រប់គ្រងបុគ្គលិក ការរៀបចំថវិកា ការអភិវឌ្ឍសមុច្ច័យឯកសារ សេវានិងការផ្សព្វផ្សាយបណ្ណាល័យ ការគ្រប់គ្រងឯកសារ តួនាទីបណ្ណាល័យក្នុងសកម្មភាពបង្រៀននិងរៀន និងប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ។

## ៥. វគ្គអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញការអប់រំស្ទែម


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១០៤២ អយក.ឋស

វិញ្ញាបនបត្រ
ទទួលស្គាល់គុណភាពការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

គណៈកម្មការសម្រាប់ ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
ផ្តល់
ការទទួលស្គាល់គុណភាពពេញសិទ្ធិ
ដល់
ការបណ្តុះបណ្តាលស្តីពី
ការអប់រំស្ទែម និងពិសោធន៍វិទ្យាសាស្ត្រ
ចំនួន ៦ ក្រេឌីត
របស់វិទ្យាស្ថានជាតិអប់រំ ដែលបានបំពេញតាមលក្ខខណ្ឌ នៃការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានរយៈពេល ០៥ ឆ្នាំ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ ដល់ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៨ ។

ថ្ងៃ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២៣
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

វគ្គបណ្ដុះបណ្ដាលនេះផ្ដោតលើការបង្រៀន និងរៀនតាមបែបវិធីស្ទែម ពិសោធន៍វិទ្យាសាស្ត្រ និងការបំប្លែងការបង្រៀនពិសោធន៍វិទ្យាសាស្ត្រឱ្យទៅជាការបង្រៀនតាមបែបស្ទែមដែលជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា។ មេរៀននីមួយៗមានពិសោធន៍ជាក់ស្ដែង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនដែលអាចជួយឱ្យសិក្ខាកាមអភិវឌ្ឍពុទ្ធិ និងសម្បទាលើវិធីសាស្ត្របង្រៀនស្ទែម និង

វិទ្យាសាស្ត្រយ៉ាងសម្បូរបែប ព្រមទាំងផ្ដល់ឱកាសឱ្យសិក្ខាកាមបានផ្លាស់ប្ដូរបទពិសោធន៍នៃការបង្រៀនស្ទែម និងពិសោធន៍វិទ្យាសាស្ត្រ។ កម្មវិធីបណ្ដុះបណ្ដាលនេះមានរយៈពេល១៥សប្ដាហ៍ និងបែងចែកជា៩០ម៉ោង (៦ក្រេឌីត)។ កម្មវិធីបណ្ដុះបណ្ដាលការអប់រំស្ទែម និងពិសោធន៍វិទ្យាសាស្ត្រផ្ដោតលើកញ្ចប់មុខវិជ្ជាធំៗចំនួន២គឺ៖

ទី១៖ ការអប់រំស្ទែម (៤៥ម៉ោង ស្មើនឹង៣ក្រេឌីត)
ទី២៖ ពិសោធន៍វិទ្យាសាស្ត្រ (៤៥ម៉ោង ស្មើនឹង៣ក្រេឌីត)

តារាងខាងក្រោមបង្ហាញពីកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើមុខជំនាញទាំង៥ ដែលត្រូវបានអនុវត្តពីខែឧសភា ឆ្នាំ២០២២ មកដល់ខែឧសភា ឆ្នាំ២០២៥ ចំនួន៩វគ្គ ដែលមានសិក្ខាកាមសរុប ៥២៦៩នាក់ (ស្រី៣៣៩៥)។

| វគ្គ | សិក្ខាកាមតាមជំនាញ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៣២៦ | ២៧៣ | ២១/០៥/២០២២-១១/០៩/២០២២ |
| | វិជ្ជាជីវៈនាយកសាលា | ៨៨ | ២៧ | |
| ២ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៣៤៥ | ២៣៨ | ០៣/១០/២០២២-១៤/០១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៦៨ | ២២ | |
| ៣ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៣៣១ | ២១៧ | ០៤/០៣/២០២៣-១៦/០៦/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៥៩ | ២៤ | |
| ៤ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៣៤៧ | ២៤៧ | ២៩/០៧/២០២៣-១៨/១១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៩២ | ២៣ | |
| ៥ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៨០៥ | ៥៤១ | ០៩/១២/២០២៣-១៨/០២/២០២៤ |
| | វិជ្ជាជីវៈនាយកសាលា | ៦៤ | ១៩ | |
| | ការអប់រំស្ទែម និងពិសោធវិទ្យាសាស្ត្រ | ១៦ | ៦ | |
| | ការគ្រប់គ្រងបណ្ណាល័យមធ្យមសិក្សា | ៥ | ៤ | |
| | ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ | ២៣ | ៧ | |
| ៦ | គរុកោសល្យនិងវិធីសាស្ត្របង្រៀន | ៣៤៤ | ២៣៩ | ២៩/០៧/២០២៣-១៨/១១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៣១ | ១៥ | |
| | ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ | ១២ | ១ | |

| | | | | |
|---|---|---|---|---|
| ៧ | គរុកោសល្យនិងវិធីសាស្រ្តបង្រៀន | ៤៨៨ | ៣៤៧ | ២៩/០៧/២០២៣-១៨/១១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៣៩ | ១៤ | |
| | ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ | ២៧ | ១០ | |
| ៨ | គរុកោសល្យនិងវិធីសាស្រ្តបង្រៀន | ៨០៧ | ៥៣៨ | ២៩/០៧/២០២៣-១៨/១១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៤២ | ១៥ | |
| | ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ | ១៧ | ៧ | |
| ៩ | គរុកោសល្យនិងវិធីសាស្រ្តបង្រៀន | ៧៣៥ | ៣៤៧ | ២៩/០៧/២០២៣-១៨/១១/២០២៣ |
| | វិជ្ជាជីវៈនាយកសាលា | ៥០ | ១៧ | |
| | ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ | ៣៨ | ១៦ | |
| | សរុប | ៥២៦៩ | ១៦ | |

ជំពូក
៥

# ការស្រាវជ្រាវអប់រំ និងនវានុវត្តន៍

## ការស្រាវជ្រាវអប់រំ

ការស្រាវជ្រាវអប់រំគឺសសរស្តម្ភមួយទៀត របស់វិទ្យាស្ថានជាតិអប់រំ។ គោលបំណងចម្បងនៃការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ គឺដើម្បីចូលរួមចំណែកតម្រង់ទិស កំណែទម្រង់អប់រំ ស្របតាមចក្ខុវិស័យអភិវឌ្ឍជាតិ និងនិន្នាការអប់រំថ្មីក្នុងតំបន់ និងសាកលលោក។

មជ្ឈមណ្ឌលស្រាវជ្រាវអប់រំ និងនវានុវត្តន៍ ដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់ការស្រាវជ្រាវអប់រំ តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០២៦-២០៣០) ដែលមានយុទ្ធសាស្ត្រគោលដូចខាងក្រោម៖

- យុទ្ធសាស្ត្រ១៖ ផ្សារភ្ជាប់សកម្មភាពតម្រង់ទិសស្រាវជ្រាវ និងសកម្មភាពសិក្សាស្រាវជ្រាវទៅនឹងគោលនយោបាយអប់រំ កំណែទម្រង់អប់រំ និងការអនុវត្តការបង្រៀន និងរៀន
- យុទ្ធសាស្ត្រ២៖ ភ្ជាប់ការចូលរួមពីសាស្ត្រាចារ្យនិងគ្រូឧទ្ទេសដែលមកពីដេប៉ាតឺម៉ង់ មហាវិទ្យាល័យ សាលាផ្សេងៗលើផ្នែកស្រាវជ្រាវ
- យុទ្ធសាស្ត្រ៣៖ ជំរុញការចូលរួមពីដៃគូ និងភាគីពាក់ព័ន្ធពីខាងក្រៅ ក្នុងការគាំទ្រ និងផ្តល់ធនធានស្រាវជ្រាវ
- យុទ្ធសាស្ត្រ៤៖ ផ្តល់ជូនការបណ្តុះបណ្តាលផ្នែកកសាងសមត្ថភាពស្រាវជ្រាវ និងឱកាសទទួលបានការបង្វឹកបន្ថែម
- យុទ្ធសាស្ត្រ៥៖ គាំទ្រការបង្កើតយន្តការការងារស្រាវជ្រាវដែលមានសុខដុមនីយកម្ម និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននិងស្ថាប័ន
- យុទ្ធសាស្ត្រ៦៖ ជំរុញផលិតភាពការបោះពុម្ពផ្សាយការស្រាវជ្រាវកម្រិតអន្តរជាតិ ដែលមានគុណភាពខ្ពស់
- យុទ្ធសាស្ត្រ៧៖ លើកកម្ពស់លទ្ធផលស្រាវជ្រាវដែលពាក់ព័ន្ធនឹងការអនុវត្ត និងការអប់រំឌីជីថល

ការស្រាវជ្រាវអប់រំនឹង ផ្តោតលើការអភិវឌ្ឍវិធីសាស្ត្របង្រៀន និងការរៀនសូត្រដែលសមស្របនឹងយុគសម័យឌីជីថល។ ការស្រាវជ្រាវនឹងរួមបញ្ចូលការសិក្សាអំពីប្រសិទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងការទំនាក់ទំនង (ICT) និងបញ្ញាសិប្បនិម្មិត (AI) ក្នុងការអប់រំ ព្រមទាំងការលើកកម្ពស់សមត្ថភាពរបស់គ្រូបង្រៀនក្នុងការបង្រៀនតាមបែបរិះរក (Inquiry-Based Learning)។ ក្រៅពីនេះ ការស្រាវជ្រាវផ្តោតលើការសិក្សាអំពីឥទ្ធិពលនៃការអប់រំឌីជីថលលើលទ្ធផលសិក្សារបស់សិស្ស និងការរីកចម្រើននៃការអប់រំបច្ចេកទេស។ ការស្រាវជ្រាវអប់រំ នឹងត្រូវបន្តរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់ប្រព័ន្ធអប់រំនៅកម្ពុជា ដើម្បីធានាសិស្សនឹងក្លាយទៅជាពលរដ្ឋពេញលេញ នាពេលអនាគត។

## បណ្ណាល័យ

បណ្ណាល័យ គឺជាកន្លែងរៀនសូត្រ និងស្រាវជ្រាវប្រកបដោយនវានុវត្តន៍មួយ គាំទ្រដល់ការរៀន និងបង្រៀន ស្របតាមទិសស្លោក «អ្នកអាន ជាអ្នករៀនពេញមួយជីវិត»។ បណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត នៃវិទ្យាស្ថានជាតិអប់រំ មានចក្ខុវិស័យ ក្នុងការប្រែក្លាយជាបណ្ណាល័យឌីជីថលប្រកប ដោយឧត្តមភាពឈានមុខគេ លើផ្នែកសិក្សាធិការសម្រាប់សហគមន៍នៃការអប់រំគ្រូបង្រៀន និងមានបេសកកម្ម ក្នុងការផ្តល់សេវាបណ្ណាល័យដល់អ្នកសិក្សា គ្រូបង្រៀន និងអ្នកស្រាវជ្រាវលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ការបង្រៀន និងរៀន និងអ្នកគ្រប់គ្រងអប់រំ។ ផែនការយុទ្ធសាស្ត្របណ្ណាល័យសម្តេចព្រះសង្ឃរាជ ជួន ណាត មានយុទ្ធសាស្ត្រគោល ដូចខាងក្រោម៖

- យុទ្ធសាស្ត្រ១៖ កសាងឧត្តមភាពបណ្ណាល័យប្រកបដោយនវានុវត្តន៍ ដើម្បីគាំទ្រដល់តម្រូវការសិក្សាក្នុងវជអ
- យុទ្ធសាស្ត្រ២៖ អភិវឌ្ឍធនធានមនុស្សដោយផ្សារភ្ជាប់ទៅនឹងការគាំទ្រដល់បណ្ណាល័យ
- យុទ្ធសាស្ត្រ៣៖ បណ្តុះវប្បធម៌នៃការជឿទុកចិត្ត សុខុមាលភាព និងកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រដល់បេសកកម្មរបស់វជអ
- យុទ្ធសាស្ត្រ៤៖ លើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការគាំទ្របណ្ណាល័យ
- យុទ្ធសាស្ត្រ៥៖ ពង្រឹងរចនាសម្ព័ន្ធសម្រាប់គាំទ្រ ការប្រើប្រាស់ធនធានបណ្ណាល័យ
- យុទ្ធសាស្ត្រ៦៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបណ្ណាល័យ ដើម្បីគាំទ្រដល់ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងការរៀន ការបង្រៀន និងការស្រាវជ្រាវប្រកបដោយឧត្តមភាពរបស់វជអ
- យុទ្ធសាស្ត្រ៧៖ បង្កើនបំណិនស្រាវជ្រាវដល់បណ្ណារក្ស
- យុទ្ធសាស្ត្រ៨៖ បង្កើនកេរ្តិ៍ឈ្មោះបណ្ណាល័យដោយផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងកម្មវិធីសិក្សាក្នុងវជអ សហការជាមួយគ្រូឧទ្ទេស បណ្ណារក្សនៅកម្រិតមធ្យមសិក្សា។
- យុទ្ធសាស្ត្រ៩៖ ពង្រឹងទំនាក់ទំនងជាមួយបណ្ណាល័យកម្រិតជាតិ តំបន់ និងអន្តរជាតិ



*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*
*និងឯកឧត្តមបណ្ឌិត ឌី ខាំបូលី ប្រធានគណៈកម្មាធិការកំណែទម្រង់វិទ្យាស្ថានជាតិអប់រំ*
*ពិនិត្យមើលផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តវិទ្យាស្ថានជាតិអប់រំ (៦ មេសា ២០២២)*

